# ព្រះសម្គាល់អង្គទ្រង់ដោយ លក្ខណៈពិសេសរបស់ទ្រង់

ខ្ញុំគ្រាន់តែភ្ញាក់ផ្អើល នៅពេលដែលខ្ញុំបានឃើញមិត្តរបស់ខ្ញុំ គាត់គឺ យ៉ូសែប ប៊ូស គាត់ នៅទីនោះ ហើយខ្ញុំក៏បានបែរមកចាប់ដៃរាក់ទាក់ គាត់បន្តិច។

2 ឥឡូវសូមបើកទៅព្រះបន្ទូលរបស់ព្រះ គឺនៅហេព្រើរ ជំពូកដំបូងបង្អស់។ ខ្ញុំចង់អានផ្នែកខ្លះក្នុងខ ទី១ ទី២ និងទី៣ សម្រាប់ទាញយកអត្ថបទយប់នេះ។

*ឯព្រះ ដែលពីដើម ទ្រង់មានព្រះបន្ទូលនឹងពួកឰយុកោ ដោយពួកហោរា ជាច្រើនដងច្រើនបែប នៅជាន់ក្រោយបង្អស់នេះ ទ្រង់បានមានព្រះបន្ទូលនឹងយើងរាល់គ្នា ដោយសារព្រះរាជបុត្រាវិញ ដែលទ្រង់បានតម្រូវឲ្យបានគ្រងរបស់ទាំងអស់ ទុកជាមរដក ព្រមទាំងបង្កើតលោកីយ៍ ដោយសារព្រះរាជបុត្រានោះដែរ*

*គឺទ្រង់ជារស្មីភ្លឺមកពីសិរីល្អនៃព្រះ ហើយជារូបភាពនៃអង្គទ្រង់ ទាំងទ្រទ្រង់គ្រប់របស់ទាំងអស់ ដោយសារព្រះបន្ទូលដ៏មានព្រះចេស្តានៃទ្រង់ ហើយក្រោយដែលបានសំអាតអំពើបាប របស់យើងរាល់គ្នាទាំងប៉ុន្មាន នោះក៏គង់នៅខាងស្តាំនៃឫទ្ធានុភាពនៅលើស្ថានដ៏ខ្ពស់*

3 ចូរយើងឱនក្បាលដើម្បីអធិស្ឋាន។ ហើយឥឡូវនេះ នៅក្នុងព្រះវត្តមាន របស់ទ្រង់ បើសិនអ្នកមានសំណូមពរ អធិស្ឋានទូលដល់ទ្រង់ សូមលើកដៃឡើង នោះការសូមរបស់អ្នកព្រះនឹង…

4 ឱព្រះវបិតានៃស្ថានសួគ៌អើយពួកយើងមកទីនេះ ចូលទៅចំពោះបល្ល័ង្ករបស់ទ្រង់ ដោយសេចក្តីជំនឿនៅក្នុងព្រះនាមនៃ ព្រះយេស៊ូវ គ្រីស្ទ ដែលជាព្រះរាជបុត្រានៃព្រះ។ ហើយយើងខ្ញុំជឿជាក់ថា "បើសិនជា យើងទូលសូមដោយនូវព្រះនាមនៃព្រះអង្គ ទ្រង់នឹងទទួល។" ហើយ ទ្រង់ជ្រាបនៅបំណងប្រាថ្នា និងសេចក្តីត្រូវការទាំងអស់របស់យើង ហើយទ្រង់សន្យា នឹងប្រទានគ្រប់ទាំងតម្រូវការ ដែលយើងត្រូវការ។ ដូច្នេះ ព្រះអង្គម្ចាស់ អើយ យើងសូមអធិស្ឋានតាមសេចក្តីបង្រៀនរបស់ទ្រង់ "រាជរបស់ទ្រង់បានមកដល់។ សូមឲ្យព្រះហឫទ័យទ្រង់បានសម្រេច នៅ

ផែនដីដូចនៅស្ថានសួគ៌ដែរ។" នោះជាសេចក្តីអធិស្ឋាន របស់យើងទាំងអស់គ្នា នៅយប់នេះ សូមតាមបំណងព្រះហឫទ័យទ្រង់ ហើយផ្តល់ឯកសិទ្ធិនេះដល់ យើង ព្រះអង្គអើយ។ សូមតាំងព្រះបន្ទូល ព្រះអម្ចាស់នៅលើអ្នកអធិប្បាយ និងអ្នកដែលស្តាប់នៅទីនេះ សូមឲ្យព្រះវិញ្ញាណបរិសុទ្ធយាងមកធ្វើកិច្ចការតាមព្រះបន្ទូល នៅយប់នេះក្នុងចំណោមយើង។ ដ្បិតយើងទូលសូម ដោយ នៅក្នុងព្រះនាមទ្រង់ អេម៉ែន។

សូមអញ្ជើញអង្គុយចុះ។

5 ព្រឹកស្អែកខ្ញុំដឹងថា វាជាពេលអាហារពេលព្រឹក របស់ក្រុមអ្នកផ្សាយដំណឹងល្អ។ ជាធម្មតា កន្លែងណាដែលពួកគេមានការប្រកបគ្នាខ្ញុំតែងតែមានអភ័យឯកសិទ្ធក្នុងការចែកចាយ ពេលអាហារពេលព្រឹក។ នៅពេលនេះ វាជាអង្គភាពមួយដែលមិនមែនជាអង្គការប៉ុន្តែគ្រាន់តែជាក្រុមប៉ុណ្ណោះខ្ញុំ—ខ្ញុំក៏នៅក្នុងក្រុមអ្នកជំនួញគ្រីស្ទាននេះដែរ។ ហើយឥឡូវនេះ ខ្ញុំនឹងចែកចាយ ជាអន្តរជាតិ។

6 ឥឡូវនេះ នៅយប់នេះ យើងជឿជាក់ថាការប្រជុំនេះមិនឥតប្រយោជន៍ទេ។ ខ្ញុំមករកអ្នកយ៉ាងហត់នឿយ និយាយឡើងស្អកករ ហើយបានទទួលខ្យល់ដង្ហើមបន្តិចបន្តួចពី...

7 ខ្ញុំមកពីទីក្រុង តាកសាន់ ដែលជាកន្លែងដែលល្អ ហើយក្តៅ តែខ្ញុំមក ទីនេះ វាជាកន្លែងដែលល្អ ហើយត្រជាក់ ដូច្នេះវាមានលក្ខណៈខុសគ្នា ឆ្ងាយណាស់។ បើសិនជាអ្នកយកទឹកពីទីនេះ ហើយបញ្ជូនវាទៅ កន្លែងរបស់យើងបាន ខ្ញុំសូមសសើរ។ ប៉ុន្តែ ពិតណាស់អ្នកមិនអាចធ្វើអ៊ីចឹងបានទេ ។

8 ប៉ុន្តែ ខ្ញុំប្រាប់អ្នករឿងមួយ មានការប្រៀបធៀបមួយនៅទីនោះ។ របស់ទាំងអស់—របស់យើង—របស់យើងនៅអារីសូណា ដើមឈើរបស់យើង វាពេញទៅដោយស្នាម។ គ្រប់ដើមឈើទាំងអស់មានស្នាម។ នោះដោយសារតែវាក្តៅ ហើយស្ងួត។ ឥឡូវ បើសិនជាវាជាព្រៃដូចគ្នាដែលដុះនៅទីនេះ វានឹងលាស់ស្លឹកគួរអោយស្រលាញ់។ ឃើញទេដោយសារគ្មានទឹកដែលជាមូលហេតុធ្វើឲ្យវាមានស្នាម។

9 ហើយប្រសិនបើ ក្រុមជំនុំរីកចម្រើនដោយគ្មានទឹកនៃជីវិត ដូចគ្នាដែរ វានឹងស្ងួត ហើយស្វិតក្រៀមស្រពោនគ្រប់ទាំងមែកនិងធៀង។ ប៉ុន្តែ កន្លែងដែលទឹកនៃជីវិតហូរកាត់វានឹងបើកស្លឹកឡើងហើយធ្វើឲ្យវាទន់ រលោង សម្លេងក៏ពិរោះ បរិសុទ្ធ

ដែលព្រះអាចទទួលយកបាន។ ដូច្នេះ សូមអោយព្រះជាម្ចាស់ បានប្រទានទឹកសម្រាប់យើង នៅយប់នេះ ហើយកុំអោយ យើងមានការក្រៀមស្វិតឡើយ។ ប៉ុន្តែយើងនឹងក្លាយជា ស្លឹកដ៏ល្អដែលមនុស្សចង់អង្គុយ ក្រោមម្លប់របស់យើងនិងស្វែងរកការសម្រាកសំរាប់ព្រលឹងពួកគេ។

10 ឥឡូវនេះ ខ្ញុំចង់យកអត្ថបទនៅយប់នេះ បើសិនជា ព្រះសព្វហឫទ័យ ខ្ញុំនឹង ខិតជិតមេក្រូតូចនេះ ដូចដែលអាចធ្វើបាន ពីព្រោះមាន សម្លេងខ្សោយ។ ខ្ញុំចង់អានហេព្រើរ ជំពូក១ខ១ ខ្ញុំយកអត្ថបទដែលនិយាយអំពី *ព្រះសម្គាល់អង្គទ្រង់ដោយលក្ខណៈពិសេសរបស់ទ្រង់ផ្ទាល់*។ ខ្ញុំនឹងអានវា ម្តងទៀត ដោយសារតែសម្លេងរបស់ខ្ញុំ វាលឺតិចពេក។ ព្រះសម្គាល់អង្គទ្រង់ ដោយលក្ខណៈពិសេសរបស់ទ្រង់ផ្ទាល់។

11 ឥឡូវ របស់ជាច្រើនយើងអាចសម្គាល់វា ដោយលក្ខណៈពិសេសរបស់វា។ ហើយខ្ញុំមានខគម្ពីរខ្លះ ខ្ញុំអាច...និងកត់ត្រា នោះជាការ ដែលខ្ញុំចង់សំដៅលើ។ ឥឡូវនេះ លក្ខណៈពិសេសនៃគ្រប់របស់ទាំងអស់ គឺអាចសម្គាល់បាន ថាវាជាអ្វី។

12 ឥឡូវ ដូចជាធម្មជាតិទាំងអស់ រួមមានផ្កាដែលយើងបានស្គាល់ ភាគច្រើន គឺយើងអាចស្គាល់ ដោយសារលក្ខណៈពិសេសរបស់វា។ បើសិនជា វាដុះនៅជិតគ្នារវាងប្រភេទមួយនិងប្រភេទមួយទៀត លក្ខណៈរបស់វា យើង នឹងសម្គាល់បានថាផ្កានោះជាផ្កាអ្វី។ ហើយនៅក្នុងព្រៃ ភាគច្រើន...

13 ខ្ញុំ—ខ្ញុំគឺជាអ្នកប្រមាញ់។ ហើយអ្នក ត្រូវតែដឹងពី លក្ខណៈពិសេស នៃសត្វដែលអ្នកកំពុងតែប្រមាញ់ ឬពេលខ្លះអ្នកអាចនឹងត្រូវបញ្ឆោត។ ឧទាហរណ៍ ដូចជាការសម្គាល់ផ្លូវទៅ ចក្រភពអង់គ្លេស នៅទីក្រុងកាឡុំបៀ។ ខ្ញុំបានដើរទៅដល់យុកនមានបងប្អូនពីរនាក់ ដែលបានដើរជាមួយខ្ញុំហើយយើងបានធ្វើការបរបាញ់។

14 ឥឡូវនេះ បើសិនជាអ្នកមិនដឹងពីភាពខុសគ្នា នៅពេលណាអ្នកបាញ់ចៀម ឬរមាំងទេ អ្នកមិនអាចប្រាប់ពីលក្ខណៈពិសេសរបស់វាបានទេ លុះត្រាតែអ្នកគឺជាអ្នកប្រមាញ់ឆ្លាតវៃ។ ពីព្រោះពួកវាមានលក្ខណៈស្រដៀងគ្នា នៅពេល ដែលពួកវាដើរ និងរត់។ ហើយអ្នកឃើញទេ បក្សីមួយក្បាល គឺទុំនៅទីនោះ សូមមើលវា ហេតុអ្វីបានជាអ្នក—អ្នក ចង់ដឹងពីភាពខុសគ្នារបស់វា។ ពួកវាមាន រូបរាងស្រដៀងគ្នាស្ទើរគ្រប់ផ្នែក វាមានពណ៌ស ដូចក្តាន់ដែរ។ ខ្ញុំមាន ការពិបាកណាស់នៅពេលដែលខ្ញុំប្រាប់ពីពួកវា។ ប៉ុន្តែស្នែងរបស់វាអាចសម្គាល់ពីលក្ខណៈពិសេស

របស់វា គឺស្នែងរបស់វា។ ចៀម មានស្នែងមូល ចូលក្នុង ហើយរមាំង មានស្នែងវែងៗ បែកចេញច្រើន។ ហើយ លក្ខណៈពិសេស ផ្សេងទៀតគឺ រមាំងលើក ជើងខ្ពស់ៗ នៅពេលដែលវាដើរ។

15 ហើយពពែដើរជាលក្ខណៈរបស់ពពែ ហើយចៀមក៏ដូចគ្នាដែរ ដែលអ្នកគួរតែដឹងពីលក្ខណៈខុសគ្នារបស់វាអ្នកត្រូវឈរលើកំពូលដ៏ខ្ពស់ព្រោះពួកវាទាំងពីប្រភេទ នេះតែងតែនៅលើភ្នំ។ អ្នកគួរតែដឹងពីលក្ខណៈខុសគ្នារបស់ពួកវា។ ប៉ុន្តែអ្នកត្រូវកត់—សម្គាល់ថាពពែជំពប់ដូចដើរ ពេលចៀមអង្គុយជើងរបស់វាសំយ៉ុងចុះដូច *នេះ* ដូចដើរ។ លក្ខណៈនៃវិធីដែលវារស់នៅ។ អ្នកអាចសម្គាល់សកម្មភាពរបស់អ្នកដោយលក្ខណៈដែលវាដំណើរការ ហើយរបៀបដែលវាធ្វើ និងអ្វីដែលវាស៊ី និង អ្វីៗទាំងអស់។ វាត្រូវបានសម្គាល់ដោយលក្ខណៈពិសេសរបស់វា។ហើយអ្នកអាច លោតបន្តិចហើយមើលអ្វីដែលកើតឡើង អ្នកអាចប្រាប់ពីវិធីដែល ពួកវាទៅ។ អ្នក អាចប្រាប់តាមរយៈលក្ខណៈនៃសត្វផ្សេងគ្នាបាន។

16 បន្ទាប់មក តើអ្នកធ្លាប់កត់សម្គាល់ទេ ខ្ញុំមិនដឹងថាអ្នក មានវានៅទីនេះឬអត់ ឬអត់ទេបក្សីពណ៌លឿង ប្រហែលបក្សីលឿងគឺជាឈ្មោះត្រឹមត្រូវរបស់ពួកវា ហើយនឹងប្រភេទនៃបក្សីចាយដែរ។ បក្សីចាយវាមានរូបរាងស្រដៀងនឹង បក្សីលឿងដែរ។ ហើយអ្នកឃើញបក្សីពីរក្បាលទេ ពួកវាកំពុងតែហើរ ពួកវាទាំងពីរជាប្រភេទបក្សីដូចគ្នា។ បើសិនជា អ្នកអត់ឃើញពណ៌របស់វាទេ ដោយគ្រាន់តែមើលវាសិន អ្នកនឹងអាចទាយបានថា មួយណាជា បក្សីលឿង។ បក្សីចាយអាចហើរតិចឬច្រើនតែហើរត្រង់។ ប៉ុន្តែបក្សីលឿង វាប្រើស្លាបរបស់វាដូចរុំ វាទទះស្លាបហើរឡើងលើ ចុះក្រោមឡើងលើចុះក្រោម។ ឃើញទេ វាបានចងខ្លួនឯងដូច*នោះ* ហើយអ្នកអាចប្រាប់បានពីលក្ខណៈរូបរបស់បក្សីលឿង នៅពេលដែលវាហើរ។

17 បើសិន អ្នកបានកត់សម្គាល់—អំពីគ្រួច នៅពេលដែលវាចេញ របៀបដែលវាចេញ។ ហើយមើល ហើយបើសិនជាអ្នកនៅក្នុងភក កន្លែងដែលគ្រួចអាចរស់នៅ—ជាបក្សីវាលភក។ អ្នកបរបាញ់ត្រូវដឹងពីការនោះ។ បក្សីវិលសាន់ និង បក្សីចេកពួកវាអាចសម្គាល់ខ្លួនរបស់ពួកវាបានដោយសាររបៀបនៃការចេញនិង របៀបដែលវាហើរ។ ពួកវាសម្គាល់ខ្លួនរបស់ពួកវា ដោយការហើរ ដូចដែល ពួកវាជាប្រភេទនៃបក្សីដូចគ្នា។ ដូច្នេះ បើអ្នកគ្រាន់តែលឺពីពួកវា អ្នកនឹងដឹងពី កន្លែងដែលពួកវា

រស់នៅដែរ វាចេញមកពីណា វាជាសត្វអ្វី អ្នកអាចសម្គាល់វាបាន នៅពេលដែលវាហើរមក។

18 ដូចជា បុរសម្នាក់និងស្ត្រីម្នាក់។ ពួកគេគឺជាមនុស្ស ប៉ុន្តែ មនុស្សស្រីមានលក្ខណៈពិសេសខុសពីបុរស។ ខ្ញុំបានអាននៅទីនេះជាយូរមកហើយ អំពីស្តេចសាឡូម៉ូន និងម្ចាស់ក្សត្រី។ ខ្ញុំមិនដែលបានអធិប្បាយ ពីចំនុចនេះទេ ម្ចាស់ក្សត្រីភាគខាងត្បូងដែលមកឯស្តេចសាឡូម៉ូននិងមើលពីអំណោយទាននៃការវិនិច្ឆ័យ។ ខ្ញុំបានអានពីរឿងនេះមិនយូរប៉ុន្មានទេ វាបាននិយាយអំពី "ល្បែងផ្គុំរូបនោះបានដាក់ពីមុខ សាឡូម៉ូនម្ចាស់ក្សត្រីបានយកស្ត្រីម្នាក់ឬក៏ស្ត្រីឲ្យស្លៀកពាក់ជាបុរស។"

19 ឥឡូវ នោះជាបរទេស នៅថ្ងៃនោះ ប៉ុន្តែជាការពិត មកដល់—ថ្ងៃ—នេះ នៅថ្ងៃនេះ។ ហើយ—ហើយអ្នកដឹងថាវាជាការខុស។ ព្រះគម្ពីរមានព្រះបន្ទូលថាស្ត្រីមិនគួរធ្វើដូចនោះទេ។ "វាគួរឲ្យស្អប់សំរាប់ស្ត្រី ស្លៀកសម្លៀកបំពាក់បុរសហើយធ្វើចរិកប្រុស។" ហើយព្រះដែលមិនផ្លាស់ប្រែបានមានបន្ទូល ដូច្នេះ នោះគឺជាការពិត។

20 ដូច្នេះ យើងឃើញថាស្តេចសាឡូម៉ូន មិនបានមើលទៅពួកគេទេ ទ្រង់គ្រាន់តែឲ្យពួកគេដើរឬធ្វើអ្វីមួយនោះទ្រង់មានបន្ទូលភ្លាម"គឺជាស្ត្រី។" ឃើញទេទ្រង់អាចប្រាប់តាមរយៈលក្ខណៈពិសេស នៃស្ត្រីនោះបាន របៀបដែលនាងធ្វើអាចបញ្ជាក់បានថា នាងជាមនុស្សស្រីមិនមែនជាមនុស្សប្រុសទេ។

21 ហើយ ភាគច្រើន គឺបែបនោះតាមលក្ខណៈពិសេសរបស់វា។ គ្រាន់តែ មនុស្សខ្លះឆ្វេងដៃនិងខ្លះទៀតស្តាំដៃ។ ពួកគេជាចរិកលក្ខណៈនៃរបៀប ដែលពួកគេប្រព្រឹត្តិរបស់ពួកគេផ្ទាល់។ អ្នកអាចប្រាប់បាន ថាតើម្នាក់នេះ ឬម្នាក់ណា ដែលប្រើដៃស្តាំ រឺដៃឆ្វេងដោយមើលពីការដែលពួកគេបានធ្វើ ហើយពីរបៀបដែលពួកគេប្រើ តើដៃឆ្វេង ឬដៃស្តាំ។

ហើយ ចូរចងចាំថា ព្រះយេស៊ូវ មានអ្វីមួយស្រដៀងដូច្នេះ ដូច្នេះដែរ...

22 ដៃទាំងពីរគឺមានលក្ខណៈជិត...ពួកវាស្រដៀងគ្នា។ ពួកវាជាប្រភេទ នៃស្នាមមេដៃដូចគ្នា ស្នាមម្រាមដៃ ម្រាមដៃប្រាំ រូបរាងតូចហើយវាសម្រាប់ចង្អុលជាដើម។ គ្រាន់តែស្តាំដៃ និងឆ្វេងដៃមានប្រភេទខុសគ្នា តែជាម្រាមដៃដូចគ្នា ជាធម្មតាដៃមានទំហំដូចគ្នានិងស្រដៀងគ្នាណាស់។ ហើយវាមានសភាពខុសគ្នាតែមួយគត់គឺ ម្ខាងជាដៃស្តាំ ហើយម្ខាងទៀត ជាដៃឆ្វេង។ នោះគឺជាផ្នែកមួយ

ដែលអាចប្រាប់ពីភាពខុសគ្នានេះ។ គឺម្ខាង ជាដៃស្តាំ ហើយម្ខាងផ្សេងទៀតជាដៃឆ្វេង។

23 ដូច្នេះបន្ទាប់មកនៅក្នុងនោះព្រះយេស៊ូវមានបន្ទូលថា...ខ្ញុំប្រហែលជានិយាយពីចំណុចនេះបន្តិច។ ព្រះយេស៊ូវមានបន្ទូលនៅក្នុងព្រះគម្ពីរ ម៉ាថាយ ជំពូក២៤ថា "លក្ខណៈពិសេស នៃព្រះវិញ្ញាណនេះ នឹងមានសភាពដូចគ្នា នៅក្នុងថ្ងៃចុងបញ្ចប់នៃផែនដីនេះ ជិតដល់ហើយ វាអាចបញ្ឆោតយើង ពីភាពខុសគ្នា តាមដែលវាអាចធ្វើទៅបាន។" ឃើញទេ ពួកគេគ្រាន់តែ...

24 អ្នកអាចយកដៃរបស់អ្នក ហើយគ្រាន់តែក្តាប់វា។ ឃើញទេ ប្រសិនបើ អ្នកមិនបានស្គាល់ពួកគេទេ។ មើលទៅដៃម្ខាង ដូចគ្នាទៅនឹងដៃម្ខាងទៀត ប៉ុន្តែមួយ គឺដៃឆ្វេង និងមួយផ្សេងទៀត គឺដៃស្តាំ។

25 នោះ គឺជាការកំណត់ចំណាំ នៃវិញ្ញាណនៅថ្ងៃចុងបំផុតដែរ។ ពួកវាមានលក្ខណៈដូចគ្នាស្ទើរគ្រប់ទីកន្លែង ប៉ុន្តែ ពួកគេមានលក្ខណៈពិសេសមួយ ដែលយើងអាចសម្គាល់បាន។ មួយគឺត្រូវនិងមួយទៀតខុស វាអាចសម្គាល់តាមរយៈលក្ខណៈរបស់វា។

26 ព្រះវិញ្ញាណ នៃព្រះក៏ត្រូវបានកំណត់ដោយ លក្ខណៈពិសេសរបស់ទ្រង់។ ឃើញទេ? ព្រះវិញ្ញាណនៃព្រះ និងវិញ្ញាណនៃក្រុមជំនុំ។ មានវិញ្ញាណនៃក្រុមជំនុំមួយ ហើយព្រះវិញ្ញាណនៃព្រះ ពិតជាមិនដូចគ្នានឹង វិញ្ញាណរបស់ក្រុមជំនុំឡើយ។

នោះគឺជាវិញ្ញាណនៃនិកាយមួយ។

27 មានព្រលឹងជាតិ។ នោះជាស្មារតីនៃប្រទេសជាតិមួយ។ គ្រប់ជាតិ សាសន៍ គ្រប់ពេលដែលខ្ញុំបានចូលទៅដល់ហើយបានដើរនៅទីនោះខ្ញុំបានជួប នូវវិញ្ញាណផ្សេងៗគ្នា។ ខ្ញុំបានចូលទៅក្នុងប្រទេសហ្វាំងឡង់ មនុស្ស នៅទីនោះគឺល្អៗណាស់ ប៉ុន្តែពួកគេគោរពព្រះហ្វូនូ។ ខ្ញុំបានចូលទៅក្នុងប្រទេស អាឡឺម៉ង់ គឺពួកគេមានវិញ្ញាណនៃពួកអាឡឺម៉ង់។

28 នៅទីនេះមិនយូរប៉ុន្មាន ខ្ញុំបានទៅជាមួយប្រពន្ធរបស់ខ្ញុំ នៅពេល ដែលយើងរស់នៅក្នុងរដ្ឋអិនឌៀអាយណា កាលពីពីរឆ្នាំកន្លងទៅ ក្បែរផ្សារទំនើប តូចមួយ។ ខ្ញុំទើបតែមកដល់ផ្ទះ។ យើងត្រូវទៅទីនោះ ដើម្បីទិញម្ហូប។ ហើយនៅតាមផ្លូវទៅ

ទីនោះ យើង...វាគឺជារដូវក្តៅ អ្នកប្រហែលជាមិនជឿទេ ប៉ុន្តែយើងបានឃើញស្ត្រីម្នាក់ស្លៀកពាក់...ហើយវាមើលទៅ ចំឡែកណាស់ខ្ញុំ...វាធ្វើអោយខ្ញុំភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ខ្ញុំ—ខ្ញុំបាននិយាយថា "មើលនោះ នាងមើលទៅ ចម្លែកណាស់ មើលសម្លៀកបំពាក់ ដែលនាងពាក់ទៅ។" ដែលក្នុងចំណោម ពួកគេគ្មាននរណា ស្លៀកពាក់អ៊ីចឹងទេ...មើលទៅដូចមិនមែនជាស្រីទេ។ ហើយ—ហើយ នាងនិយាយថា..."ល្អណាស់នោះ គ្រាន់ជាវិញ្ញាណពួកអាមេរិក ឃើញទេ នោះជាវិញ្ញាណនៃពួក អាមេរិក។"

29 ឥឡូវនេះវាជា វិញ្ញាណរបស់ពួកអាមេរិក វាគឺជា...នោះគួរតែជាសាសន៍គ្រីស្ទាន ប៉ុន្តែវិញ្ញាណនៃជនជាតិនេះមិនមែនជាគ្រីស្ទានទេ។ នោះអាចហៅថាជាសាសន៍គ្រីស្ទាន ប៉ុន្តែ ប្រហែលមួយលានម៉ាយពីវា នៃលក្ខណៈពិសេស។ ដូច្នេះស្ត្រីម្នាក់នេះ ខ្ញុំបាននិយាយថា...

នាងបាននិយាយថា "ល្អណាស់ តើយើងមិនមែនជាជនជាតិអាមេរិកទេឬ?"

30 និយាយ ខ្ញុំបាននិយាយថា "ទេ។ យើងរស់នៅទីនេះ។ នេះគឺជា ប្រទេសរបស់យើង។ យើង—យើង—យើងរស់នៅទីនេះ។ យើងស្រលាញ់ប្រទេស នេះណាស់។ វាគឺជាប្រទេស ដែលល្អដាច់គេនៅលើពិភពលោក។ ប៉ុន្តែ យើងមិនទាន់ក្លាយជាជនជាតិអាមេរិកដ៏ពិតប្រាកដទេ។" ខ្ញុំបាននិយាយថា "យើងបានកើតតាំងពីមុន។ ព្រះវិញ្ញាណបរិសុទ្ធបានយាងចុះមក ហើយយើងគឺ ស្ថិតនៅក្រោមអំណាច របស់ទ្រង់។ យើងមិនមែនស្ថិតនៅក្រោម អំណាចរបស់ លោកិយ៍នេះទេ។" ខ្ញុំបាននិយាយទៀតថា "នោះគឺជាមូលហេតុដែល បងប្អូនស្រី របស់យើង បានស្លៀកសម្លៀកបំពាក់ហើយមានសក់វែងតែអត់បានតែងខ្លួនអីទេ។ អ្នកឃើញទេ នោះជាចរិកលក្ខណៈដែលអាចសម្គាល់ថាពួកគេបាន 'បរិសុទ្ធទៅចំពោះ ព្រះជាម្ចាស់' ដ៏ខ្ពស់បំផុត។"

31 ដូច្នេះ យើងកំពុងស្វែងរក អាណាចក្ររបស់ព្រះ។ យើងកំពុងស្វែងរកស្តេចឲ្យយាងមកទទួលភារកិច្ច និងអាណាចក្រទ្រង់។ ហើយពួកគេអាចសម្គាល់បានដោយ—លក្ខណៈពិសេសរបស់ពួកគេ ទ្រព្យសម្បត្តិរបស់ពួកគេគឺមិននៅលើផែនដីនេះ ឬនៅលើជាតិសាសន៍នេះទេ។ គឺខ្ពស់លើសសេរីរុងរឿងទាំងអស់។ ដូច្នេះ ពួកគេ "ពួកគេកំពុងស្វែងរកទីក្រុងដែលសាងសង់ និងបង្កើតឡើងដោយព្រះ។" នោះពួកគេអាចសម្គាល់បាន។

32 សូមអោយខ្ញុំ មានសម្លេងលឺល្មម ក្នុងការអធិប្បាយនៅយប់ បន្ទាប់ៗដែរ។ ប៉ុន្តែខ្ញុំ—ខ្ញុំបាននិយាយមកមិនសូវចេញដូច្នេះ។ ឥឡូវសូមកត់សម្គាល់ពីលក្ខណៈពិសេសរបស់វា។

33 យើងបានលើកឧទាហរណ៍មួយ ដែលទាក់ទងនឹងជនជាតិ អ៊ីស្រាអែល បានទៅដល់ទឹកដីសន្យា។ ហើយព្រះជាម្ចាស់បានហៅពួកគេទៅ តាមការសន្យា របស់ទ្រង់។ ទ្រង់បានប្រាប់អាប្រាហាំថា "ពូជរបស់គាត់ នឹងនៅក្នុងជាតិសាសន៍ដ៏ខ្លាំងពូកែនេះ រយៈពេលបួនរយឆ្នាំ ហើយ ទ្រង់នឹងសង្គ្រោះពួកគេដោយ អំណាចចេស្តាដ៏អស្ចារ្យ។ ហើយពួកគេនឹងទៅកាន់ទឹកដី ដែលបានសន្យា ពោរពេញទៅដោយទឹកដោះគោនិងទឹកឃ្មុំ។" ហើយនៅសេចក្តីសន្យា ជិតមកដល់ ក៏មានស្តេចផារ៉ោន មួយ—មួយអង្គដែលមិនទទួលស្គាល់ ពីកិច្ចការដ៏អស្ចារ្យរបស់ លោកយ៉ូសែបក្នុងចំណោមពួកគេ។

34 ហើយ ព្រះជាម្ចាស់បានរើសព្យាការីម្នាក់ឈ្មោះ ម៉ូសេ។ ហើយបុរសម្នាក់នេះបានទទួលការបង្រៀន និងចំណេះដឹងពីសាសន៍អេស៊ីប។ គ្មានអីសង្ស័យនោះទេចំពោះការអស្ចារ្យ ឆ្លាត ឈ្លាសវៃ របស់គាត់ឡើយ ដ្បិតគាត់អាចបង្រៀនដោយប្រាជ្ញាជនជាតិអេស៊ីបបាន។ មើលទៅ វាហាក់បីដូចជាសមល្មម—សមល្មមជាមនុស្សអាចជួយរំដោះគេបាន។

35 ប៉ុន្តែ អ្នកឃើញទេ អ្វីទៅដែលហៅថាការរំដោះ ហើយអ្វីទៅជាការ រំដោះដែលព្រះហៅ វាមានលក្ខណៈខុសគ្នាដូចម្តេច។

36 ឥឡូវសូមយើងមើលបុរសម្នាក់នេះ និងសីលធម៌របស់គាត់។ ទ្រង់ដឹងថាគាត់កើតមក ដើម្បីសង្គ្រោះដល់រាស្ត្រអ៊ីស្រាអែល។ ប៉ុន្តែ ទន្ទឹមនឹងចំណេះដឹងរបស់គាត់ ដែលគាត់បានរៀន ព្រះបានហៅគាត់មក ដើម្បីសម្រេចការងាររបស់ទ្រង់ គាត់មានគ្រប់ទាំងអស់…គាត់មានបរិញ្ញាប័ត្រសិល្បៈ និងដុកទ័រផ្នែកទស្សនៈវិជ្ជា(PH.D) ហើយនិង LL.D ជាដើម។ ហើយ ទៅសង្គ្រោះរាស្ត្រអ៊ីស្រាអែល ហើយគាត់បរាជ័យទាំងស្រុង។

37 ឥឡូវនេះ ចំណាំ ហាក់ដូចជា គាត់កំពុងឈរនៅលើបងល្ល័ងនៅអេស៊្រីបក្លាយជាស្តេចផារ៉ោនគាត់អាចជួយសង្គ្រោះកូនចៅអ៊ីស្រាអែលបាន បន្ទាប់ពីក្លាយជាស្តេចផារ៉ោន ព្រោះគាត់ជិតនឹង—គ្រងរាជ្យ។ ប៉ុន្តែ អ្នកឃើញទេ ការ

ធ្វើបែបនោះ មិនបានសម្គាល់ពីលក្ខណៈពិសេសរបស់ព្រះក្នុងការសង្គ្រោះរាស្ត្រទ្រង់នោះទេ។

38 ទ្រង់មានព្រះបន្ទូលថា ទ្រង់អាចសង្គ្រោះពួកគេបាន។ *ទ្រង់*អាច "សង្គ្រោះពួកគេ ដោយព្រះហស្តអស្ចារ្យរបស់ទ្រង់" ហើយមិនមែនដោយកងទ័ព ដ៏ខ្លាំងក្លារបស់ម៉ូសេឡើយ ប៉ុន្តែដោយព្រះហស្តរបស់ទ្រង់ផ្ទាល់។

39 យើងបានដឹងថាព្យាការីនេះបានរត់គេចទៅនៅក្នុងវាលរហោស្ថាន អស់រយៈពេលសែសិបឆ្នាំ។ វាចំណាយពេលជាង៉ានសែសិបឆ្នាំដើម្បីហ្វឹកហាត់ចំណេះដឹង ទៅក្នុងគាត់ហើយក៏ចំណាយពេលព្រះសែសិបឆ្នាំដើម្បីយកវាចេញពីគាត់។ ដូច្នេះ យើងដឹងថា ថ្ងៃមួយគាត់បានដើរកាត់វាលខ្សាច់ ហើយបានជួបនឹងព្រះជាម្ចាស់ក្នុងកម្ពោតព្រៃកំពុងឆេះជាទំរង់សសរភ្លើងនៅគុម្ពោទព្រៃ។ ហើយគាត់ត្រូវបានបង្គាប់អោយ ដោះស្បែកជើង ដ្បិតកន្លែងគាត់ឈរជាកន្លែងបរិសុទ្ធ។ ឥឡូវនេះ សូមមើលពីការទាំងនេះ កំរិតវប្បធម៌ ជាមនុស្សមានការអប់រំ ប៉ុន្តែត្រូវបានផ្លាស់ប្តូរ ទាំងអស់បន្ទាប់ ពីគាត់បានជួបនឹងព្រះភ្លាម។ ទ្រង់បានធ្វើស្ទើរទាំងអស់...

40 ពេលខ្លះ ព្រះប្រើយើងក្នុងវិធីសាម័ញ្ញ ដែលមើលទៅដូចជាល្ងង់សម្រាប់ខាងសាច់ឈាម។ សូមចំណាំថា អ្នកដែលបរាជ័យទាំងស្រុងជាមួយនឹងទាហានអេស៊្សីប ហើយអ្វីៗ ដែលនៅជុំវិញគាត់ គឺធ្វើតាមបំណងព្រះហឫទ័យព្រះជាមួយនឹងចំណេះដឹងក្នុងអាយុសែសិបឆ្នាំនៃបឋមសិក្សា។ ឥឡូវនេះ គាត់ មានអាយុប៉ែតសិបឆ្នាំហើយ ព្រឹកនេះ គាត់បានអង្គុយជាមួយប្រពន្ធរបស់គាត់ នៅលើរទេះ ហើយមានក្មេងម្នាក់នៅលើចង្កេះរបស់ប្រពន្ធគាត់ គាត់កាន់ឈើ ច្រត់នៅដៃរបស់គាត់ហើយពួកគាត់កំពុងតែធ្វើដំណើរតាមផ្លូវ ទៅស្រុកអេស៊ីប។ អ្នកនិយាយថាជារឿងគួរឲ្យអស់សំណើច! ប៉ុន្តែនោះជាការបង្ហាញពីលចរិកក្ខណៈរបស់ព្រះព្រោះទ្រង់មានព្យាការីម្នាក់ដែលស្តាប់តាមព្រះបន្ទូលរបស់ទ្រង់។ មែនហើយ។ រឿងមួយទៀត តើអ្នកអាចស្រមៃបានទេថាចំងាយ ដែលបុរសនោះកំពុងធ្វើដំណើរទៅអេស៊្សីបនោះ វាឆ្ងាយប៉ុណ្ណា ហើយជាកន្លែងដែលគាត់ធ្លាប់បរាជ័យទៀត? ប៉ុន្តែតើវាជាអ្វី? លក្ខណៈពិសេសរបស់គាត់ យុទ្ធសាស្ត្ររបស់គាត់ បានផ្លាស់ប្តូរ។ គាត់បាន ធ្វើដំណើរទៅដោយនូវ ព្រះនាមនៃព្រះជាម្ចាស់ "**អញគឺជាអញ**" ការនោះត្រូវបានបញ្ចប់។ គាត់បានធ្វើ ព្រោះគាត់បានទៅដោយអំណាចព្រះជាម្ចាស់។

41 នៅតាមផ្លូវ នាំ អ៊ីស្រាអែលចេញទៅកាន់ទឹកដីសន្យា គាត់មានទំនាក់ ទំនង ល្អក្នុងការធ្វើការនេះជាមួយប្អូនប្រុសរបស់គាត់ ជាបងប្អូនខាងនិកាយ ឈ្មោះ ម៉ូអាប់។ ឥឡូវនេះឈ្មោះម៉ូអាប់គឺគ្មានន័យទេ គាត់មិនធ្លាប់ជឿលើអ្វីមួយ ឡើយ។ នោះគឺជាកូនរបស់កូនស្រីឡុត។ កូនម្នាក់នៅក្នុងចំណោមក្មេងនោះ—បង្កើតចេញជាសាសន៍ម៉ូអាប់។

42 ឥឡូវត្រង់ចំនុចនេះ ខ្ញុំចង់អោយអ្នកបានកត់ចំណាំ ពីសាសន៍ពីរផ្ទុយគ្នា។ ហើយនេះគឺអេស៊ីប រាងបែកខ្ញែកបន្តិច គ្មានជាតិសាសន៍ ដែលត្រូវទៅ គ្មានអ្នកគ្រប់គ្រងឬក៏ស្តេច ឬគ្មានអ្វីៗទាំងអស់គ្មានឥស្សរជនក្នុងចំណោមពួកគេ គឺមានតែប្រជាជនធ្វើដំណើរទៅកាន់ទឹកដីសន្យាប៉ុណ្ណោះ។ ហើយពួកគេត្រូវធ្វើដំណើរឆ្លងកាត់ទឹកដី ម៉ូអាប់។ នោះជាផ្លូវ ដែលទៅទឹកដីសន្យា។

43 ហើយម៉ូអាប់ក៏ជាអ្នកជឿលើព្រះយេហូវ៉ា ហើយពួកគេ មានព្យាការីម្នាក់។ ហើយប្រទេសអ៊ីស្រាអែល មានព្យាការីម្នាក់។ ប្រទេសទាំងពីរនេះ គឺមានព្យាការីដូចគ្នា។

44 ហើយឥឡូវ សូមកត់ចំណាំថា ពួកគេត្រូវធ្វើដំណើរទៅកន្លែងដែលព្យាការី នៃសាសន៍កុលសម្ព័ន្ធ មកដើម្បីដាក់បណ្តាសារដល់សាសន៍នេះ ព្រោះវាគ្រាន់តែជាអ្នកដំណើរដែលមិនមានកន្លែងពិតប្រាកដសម្រាប់ស្នាក់ប៉ុណ្ណោះ។ ដូច្នេះពួកគេធ្វើដំណើរមក។

មើលព្យាការីពីរនាក់នោះ។ នៅពេលដែលពួកគេមកដល់ជាមូលដ្ឋានពួកគេនិយាយត្រូវណាស់។ ពីព្រោះ សូមកត់សម្គាល់បាឡាមជាចាស់ទុំ បានប្រាប់ពួកគេថា "ឥឡូវ សូមធ្វើ អាសនាអោយខ្ញុំ អោយបានប្រាំពីរ។"

45 លេខប្រាំពីរ គឺជាលេខល្អសម្រាប់ព្រះជាម្ចាស់ វាតំណាងឲ្យសម័យកាលព្រះវិហារទាំងប្រាំពីរ ហើយក៏ជារយៈពេលប្រាំពីរថ្ងៃនៃការបង្កើតជាដើម។ ឥឡូវសូមកត់ចំណាំ ប្រាំពីរ ព្រះគឺបានសម្រេចនៅរយៈពេលប្រាំពីរថ្ងៃ។

46 "គ្រប់ទាំងអាសនាទាំងប្រាំពីរ គឺមានគោមួយ—មួយក្បាល។" ឥឡូវ មើលទៅអាសនា វាដូចគ្នាទៅនឹងអាសនានៅអ៊ីស្រាអែល។ ពួកវា គឺនៅក្នុងប្រទេសអ៊ីស្រាអែល ហើយដូចគ្នានិងអាសនានៅទីនេះហើយជាយញ្ញបូជាដូចគ្នា ហើយ

មានគោមួយក្បាលដូចគ្នាមានព្យាការីម្នាក់និងព្យាការីម្នាក់ទៀតដែរ។ ជាតិសាសន៍ពីរមាន លក្ខណៈផ្ទុយគ្នា។

47 នេះគឺជា ឧទាហរណ៍ដ៏ឥតខ្ចោះមួយ សម្រាប់ការរស់នៅសព្វថ្ងៃនេះ ប្រសិនបើ យើងមានពេលសម្រាប់ធ្វើវា! ចូរចំណាំថា ព្រះកំពុង ធ្វើការនេះដោយការប្រៀបធៀប ដើម្បីឲ្យយើងអាចរកឃើញពីចំនុចស្របគ្នា។

48 ឥឡូវដូចគ្នាដែរ បាឡាមតម្រូវឲ្យមានកូនចៀមមួយក្បាល នៅលើអាសនា នីមួយៗ។ ជាសំដីនៃជំនឿរបស់គាត់ក្នុងការយាងមករបស់ព្រះមេស៊ី។ កូនចៀមមួយចៀមមួយនោះគឺជាយញ្ញបូជាដូចគ្នានៅក្នុងស្រុកអ៊ីស្រាអែល និងជំរុំអ៊ីស្រាអែលក្នុង—ស្រុកម្ចូអាប់។ ការគោរពបូជាទាំងពីរនេះ គឺត្រឹមត្រូវ ប៉ុន្តែ ចូរចំណាំថា នេះគឺជាការគោរពបូជា ដែលស្ថិតនៅក្នុងគោលទ្ធិប៉ុណ្ណោះ។

49 ប៉ុន្តែព្យាការីម្នាក់នៅក្នុងជំរុំអ៊ីស្រាអែល មានលក្ខណៈពិសេសរបស់ព្រះជាម្ចាស់។ ហើយនឹងព្រះបន្ទូលរបស់ព្រះ គាត់នៅជាប់នឹង សេចក្តីសន្យារបស់ទ្រង់ ក្នុងសម័យនោះ ព្រោះគាត់ជាម្នាក់ដែលនឹងទៅកាន់ទឹកដីសន្យាដែរ។ ឃើញទេ?

50 ឥឡូវនេះ នេះគឺជាផ្នែកមួយនៃការគោរពបូជាបាឡាម បាឡាក អាចកត់សម្គាល់ ដូចម៉ូសេបានធ្វើ។

51 ប៉ុន្តែ អ្នកឃើញទេ ម៉ូសេគឺជាព្យាការីត្រឹមត្រូវ របស់ព្រះ មិនមែនត្រឹមតែមានការគោរពបូជាទេតែក៏ជាគំរូនៅចំពោះព្រះដែរ។ ឃើញទេ គាត់ នៅលើបន្ទាត់នៃកាតព្វកិច្ច គាត់នៅជាប់និងការសន្យានៅសម័យកាលនោះ មិនមែនជាសម័យកាលរបស់ណូអេទេ ប៉ុន្តែ ជាសម័យកាលបន្ទាប់។ "អញនិងនាំពួកគេទៅកាន់ទឹកដីដែលពេញដោយទឹកដោះនិងទឹកឃ្មុំ។" ពួកគេដើរលើផ្លូវរបស់ពួកគេ ហើយពួកអ៊ីស្រាអែលបានស្គាល់ព្យាការីរបស់ពួកគេ គឺលោកម៉ូសេ ជាមួយនឹងរាជសារនៅសម័យនោះ។ លក្ខណៈពិសេសរបស់ព្រះត្រូវបានបង្ហាញនៅក្នុងម៉ូសេ។ សរសេរភ្លើងបានកំពុងតាមគាត់។ គាត់ក៏មានដង្វាយធួនក្នុងការធ្វើការនេះ មិនមែនតាមរយៈពាក្យសំដីតែតាមរយៈសកម្មភាព។ មិនមែននឹងក្លាយជាអ្វីទេ តែគឺអ្វីឥឡូវនេះ!

52 ចូរកត់ចំណាំ គាត់បានធ្វើរូបពស់ពីលង្ហិន ហើយលើកឡើង សម្រាប់ព្យាបាលអ្នកឈឺ ហើយនឹងអ្នកដែលមានជំអំងឺដូច្នេះម៉ូសេបានអនុវត្តការព្យាបាលមកពីព្រះ។ គាត់មានដង្វាយធួនបាប ពស់លង្ហិនជានិម្មិតសញ្ញាថាព្រះគង់នៅក្នុងជំរុំហើយអ្នកដែលមើលទៅលើពស់លង្ហិននោះនឹងបានជា។

53 គាត់ក៏មានថ្មដាមកតាមគាត់ដែរ។ នោះគឺជានិម្មិតសញ្ញារបស់ព្រះ សម្រាប់រក្សាទឹកនៃជីវិតនៅក្នុងពួកគេសេចក្តីអំណរនិងការសង្គ្រោះដែលពួកគេមិនត្រូវវិនាសឡើយប៉ុន្តែ នឹងបានជីវិតអស់កល្បវិញ។ នោះជាប្រភេទនៃ...ថ្មដានៅវាលរហោស្ថាន ឯថ្មដានោះគឺជាព្រះគ្រីស្ទ។

54 បន្ទាប់មក ពួកគេបានធ្វើដំណើរតាមសេចក្តីសន្យា។ នោះក៏ជាអត្តសញ្ញាណមួយទៀតដើម្បីបង្ហាញពីលក្ខណៈរបស់ព្រះ។ មិនខ្វល់ថាពួកគេមានមូលដ្ឋានគ្រឹះ ផ្សេងជាមួយព្រះបន្ទូលយ៉ាងណាទេ គឺគាត់មានគោលគ្រឹះនិយម រួមទាំងអត្តសញ្ញាណ និងលក្ខណៈរបស់ព្រះនៅក្នុងពួកគេ។ ព្រះជាម្ចាស់ បានបង្ហាញដោយអង្គទ្រង់ផ្ទាល់។ ព្យាការីពីរនាក់ ទាំងពីរនាក់គឺជា ព្យាការី ហើយទាំងពីរនាក់ មានគោលគ្រឹះ ប៉ុន្តែព្រះបង្ហាញលក្ខណៈរបស់ទ្រង់ក្នុងម៉ូសេ ព្រោះគាត់មានលក្ខណៈរបស់ព្រះគង់ជាមួយគាត់។

55 ឥឡូវ ម្តងទៀត លក្ខណៈរបស់ព្រះគឺតែងតែលើសអ្វីទាំងអស់ ព្រោះទ្រង់លើសពីធម្មជាតិ។ ព្រះលើសពីធម្មជាតិ។ វាគឺមិនធម្មតាទេ តែងតែទំនើបពីមួយថ្ងៃទៅមួយថ្ងៃ។ អ្នកដឹងទេ។ ព្រះជាម្ចាស់មានការសោកស្តាយចំពោះ—ចំពោះមនុស្សគ្រប់ជំនាន់ដែលមិនទានស្គាល់ទ្រង់។

56 ហើយមិនមែនតែម្តងនោះទេដែលមនុស្សឬក្រុមមនុស្ស បានប្រមូលគ្នានៅលើរាជសារ ប៉ុន្តែពេលដែលពួកគេស្លាប់ទៅក្នុងផ្នូរ ពួកគេមិនអាចរស់ឡើងវិញបានទេ។ គ្មានប្រវត្តិសាស្ត្រទេ។ ពួកជំនុំ លូធើរៀន ព្រីសប៊ីធើរៀន មេតូឌីស បាបទីស ពេនតេកុស និងផ្សេងទៀត មិនដែលរស់ឡើងវិញនោះទេនៅពេលដែលពួកគេរួមគ្នានោះ។

ព្រះជាម្ចាស់ភ្ជាប់ជាមួយពួកគេដោយបុគ្គល។

57 ចូរកត់ចំណាំបើគិតទៅទ្រង់គឺមិនធម្មតានោះទេ។ ឃើញទេ យើងនៅក្នុងនិន្នាការនេះ ហើយយើងត្រូវតែជឿតាមវិធីនេះ*នេះ*។ ហើយព្រះជាម្ចាស់យ៉ាង

មកជាមួយនឹងព្រះបន្ទូលសន្យារបស់ទ្រង់ហើយបង្ហាញអង្គទ្រង់ផ្ទាល់ដោយព្រះបន្ទូលទ្រង់។ *ក្រុមទាំង*នេះមិនអាច ធ្វើវាបានទេ ព្រោះពួកគេមិនបានជឿដល់ព្រះជាម្ចាស់។ ឃើញទេ ពួកគេ បានកាត់ខ្លួនរបស់ពួកគេចេញពីព្រះ។

58 ដូចយ៉ូសែបដែរ គាត់ជាកូនប្រុសរបស់ហ្លួងដាវីឌ ហើយគឺជាបុរសដ៏ល្អម្នាក់ យ៉ូសែបគឺជាប្តីរបស់នាងម៉ារា។ គាត់គឺជាបុរសល្អ បើមិនជឿទេ សូមមើលព្រះគម្ពីរ អានបន្តបន្ទាប់ព្រោះ...ហើយរង់ចាំព្រះមេស៊ីយាងមក ហើយគួរតែដឹងនូវអ្វីដែលព្រះគម្ពីរបានចែង បានកើតឡើង។ អេសាយចែងថា "នាងព្រហ្មចារីនឹងប្រសូត្របានបុត្រមួយ។"

59 ល្អណាស់ ឥឡូវ គាត់បានធ្វើដំណើរជាមួយនឹងស្ត្រីនោះ គឺនាងម៉ារា នាងមានអាយុដប់ប្រាំបីឆ្នាំ ហើយគាត់មានអាយុចាស់ជាងនាងបន្តិច។ នៅពេលដែលពួកគេភ្ជាប់ពាក្យ ដើម្បីនឹងរៀបការ នាងបានបង្ហាញខ្លួនជាម្តាយម្នាក់បាត់ទៅហើយ។ ឥឡូវ វាគឺជាការលំបាករបស់ យ៉ូសែបក្នុងការដោះស្រាយបញ្ហានោះ។ គ្មានការសង្ស័យ បន្ទាប់ពីនាងម៉ារាប្រាប់គាត់ អំពីការមកលេងរបស់ទេវតាកាប្រ៊ីយ៉ែល។ ប៉ុន្តែយើងកត់ចំណាំពីចរិករបស់គាត់ដឹកនាំគាត់ គឺ គាត់មានការសង្ស័យ។

60 ឥឡូវ នាងបានដឹងថា នាងក្លាយជាម្តាយម្នាក់មុនពេលពួកគេ រៀបការ។ នៅក្នុងព្រះគម្ពីរ ការដាក់ទណ្ឌកម្មដល់ស្លាប់ គឺការគប់នឹងដុំថ្ម។ ស្ត្រីដែលមិនទាន់រៀបការ ហើយមានកូននាងត្រូវគេគប់នឹងដុំថ្ម។ គ្មានស្រីពេស្យាទេនៅប្រទេសអ៊ីស្រាអែល។ វាត្រូវបានដកចេញ។ ដូច្នេះយើងរកឃើញនៅក្នុងចោទិយកថាគឺបានចែងបែបនោះ។

61 ឥឡូវ យើងឃើញថាម៉ារា មើលទៅនាងហាក់ដូចជាកំពុងតែប្រើប្រាស់យ៉ូសែប ធ្វើជាខែលសំរាប់កិច្ចការដែលនាងបានប្រព្រឹត្តិ។ ព្រោះបើនាង ត្រូវបានរកឃើញថាមានកូនមុនពេលរៀបការគឺត្រូវគប់នឹងដុំថ្ម ហើយនាងគួរតែមានមនុស្សម្នាក់សម្រាប់ជាទីពឹងដល់នាង។ ហើយយើងដឹង ហើយថា ការនោះពិបាកណាស់ ក្នុងពេលដែលនាងកំពុងព្យាយាមធ្វើវា។

62 ប៉ុន្តែ យូស៊ែបបានមើលនាងដោយខ្សែរភ្នែកដ៏ស្រទន់ នាងបាននិយាយថា "យ៉ូសែប ទេវតាកាប្រ៊ីយ៉ែលបានប្រាប់ខ្ញុំថា 'ព្រះវិញ្ញាណបរិសុទ្ធសន្ថិតលើនាងហើយប្រសូត្រក្នុងផ្ទៃនាងដែលកើត—ចេញពីព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់គឺជាព្រះ។

ដែលយើងនឹងហៅថា "ព្រះរាជបុត្រានៃព្រះ។"" ហើយយ៉ូសែបគាត់—គាត់—គាត់ចង់ជឿលើ ការនោះដែរតែវាជាការមិនធម្មតាពេកហើយ។ នោះជាការដែលមិនធ្លាប់មានពីមុនមក។

63 ហើយនោះគឺជាការបង្រៀននៅសព្វថ្ងៃនេះ។ បើសិនជាយើងអាច...បើខ្ញុំអាចនាំមនុស្សឲ្យឃើញការមិនធម្មតាទាំងនេះ បើសិនវាបង្ហាញដោយព្រះបន្ទូល ដូច្នេះវានឹងបញ្ជាក់នូវអ្វីដែលជាលក្ខណៈនោះ។ នោះគឺជាព្រះនៅក្នុងសកម្មភាពនោះ។

64 យ៉ូសែបគួរតែដឹងការនេះ។ គាត់គួរតែដឹងពី "ស្ត្រីព្រហ្មចារីយ៍ នឹងប្រសូត្របានបុត្រមួយ។" ប៉ុន្តែ គាត់មានការស្មោះត្រង់ណាស់ចំពោះការនេះ។ គាត់មិនចង់ទុកនាងនៅដោយឡែកនោះទេ ប៉ុន្តែគាត់—គាត់បានគិតពីវិធីក្នុងការធ្វើវា។

65 ហើយទេវតានៃព្រះបានលេចមកក្នុងសុបិន្តរបស់គាត់។ តើអ្នកធ្លាប់ឆ្ងល់ទេថា ហេតុអ្វីបានជាទេវតាលេចមក ក្នុងសុបិន្តរបស់គាត់? គ្មានព្យាការីទេនៅពេលនោះ។ សុបិន្តរបស់ពួកគេគឺធម្មតា មិនត្រូវការការបកស្រាយទេ។ និយាយថា "យ៉ូសែប ពូជនៃពួកហ្លួងដាវីឌអើយ កុំអោយភ័យខ្លាចនឹងយកនាង ម៉ារាជាភរិយាឡើយ ដ្បិតបុត្រដែលនៅក្នុងផ្ទៃនាងគឺកើតចេញពីព្រះវិញ្ញាណបរិសុទ្ធទេ។" ឃើញទេ នោះគឺលែងអីហើយ។ ឃើញទេ ទេវតានោះបានពន្យល់សុបិន្តដល់គាត់ ជាលើកទីពី។ ប៉ុន្តែ អ្នកឃើញទេអត់មានព្យាការីក្នុងការបង្ហាញនូវព្រះបន្ទូលនោះទេដែលថា "ស្ត្រីព្រហ្មចារីយ៍នឹង ប្រសូត្របានបុត្រាមួយ។" ឃើញទេ? ដូច្នេះគាត់បានលេចមកអោយគាត់ឃើញ នៅក្នុងសុបិន្ត ព្រោះគាត់ជាមនុស្សម្នាក់ ដែលល្អនិងស្មោះត្រង់។

66 ហើយខ្ញុំជឿថាព្រះជាម្ចាស់នឹងយាងមក កាន់មនុស្សល្អណាម្នាក់តាមមធ្យោបាយណាមួយ និងបង្ហាញកិច្ចការរបស់ទ្រង់ទៅកាន់មនុស្សនោះ ក្នុងសម័យកាលនោះ ប្រសិនបើមនុស្សនោះត្រូវបានព្រះហៅសំរាប់សម័យកាលនោះ។

67 ឥឡូវ ប៉ុន្តែវាដូចជាមិនធម្មតា គ្រាន់តែពួកគេពិបាកយល់ពីវាប៉ុណ្ណោះ។ ប៉ុន្តែវាតែង តែលេចឡើងតាមព្រះបន្ទូលរបស់ព្រះជានិច្ច តាមសម័យកាលទាំងអស់គឺភាពមិនធម្មតា។

ឥឡូវមានមនុស្ស មួយចំនួនប្រហែលជាដើរទៅហើយនិយាយថា "ល្អ *នេះ* គឺជាការមិនធម្មតា នោះជាព្រះជាម្ចាស់។ *នេះ* គឺជាការដែលមិនធម្មតា។"

68 ប៉ុន្តែ អ្នកឃើញទេ វាត្រូវតែសម្គាល់ដោយព្រះបន្ទូល ហើយ ព្រះបន្ទូលគឺជាព្រះ។ ឃើញទេ? ហើយ នេះគឺជាលក្ខណៈនៃអត្តសញ្ញាណបង្ហាញថាជាអ្នកណា ព្រោះព្រះមានព្រះបន្ទូលថា "*ការនេះ* នឹងកើតមានឡើង" ហើយវាបានកើតឡើង។ ឃើញទេ? នេះគឺជា លក្ខណៈពិសេស នៃព្រះបន្ទូលរបស់ព្រះ អាចសម្គាល់បាន ពីអ្វីដែលកំពុងតែនឹងកើតឡើង។

69 ទ្រង់បានមានបន្ទូលថា នៅថ្ងៃចុងក្រោយ ទ្រង់នឹងប្រទានព្រះវិញ្ញានបរិសុទ្ធចុះមក។ លក្ខណៈពិសេសរបស់ទ្រង់ គឺបង្ហាញថានោះគឺជាព្រះ ព្រះបន្ទូលសន្យារបស់ទ្រង់។ ឃើញទេ វាតែងតែសម្គាល់លក្ខណៈរបស់វា។

70 ឥឡូវ គ្រប់ពេល កែតម្រូវពាក្យជានិច្ច នៅពេលដែលព្រះបន្ទូលនិយាយថាខុស។ តើអ្នកបានកត់ចំណាំទេ? នោះជាថ្ងៃរបស់លោក ណូអេ ដែលកែតម្រូវសម័យវិទ្យាសាស្ត្រ ដែលព្រះបានបង្ហូរទឹក ពីស្ថានសួគ៌មក។ នោះគឺម៉ូសេ ឃើញទេ ត្រូវបានកែតម្រូវ នៅពេលពួកគេទាំងអស់នោះបាន ដោះស្រាយនៅអេស៊ីប ហើយ វាគឺដូច្នេះ ប៉ុន្តែព្រះបន្ទូលរបស់ព្រះជាម្ចាស់ ត្រូវមកដើម្បីបង្ហាញ។ ហើយព្រះបន្ទូលពិតបានកែតម្រូវនូវកំហុសទាំងអស់។

71 ខ្ញុំសូមសួរសំនួរទៅអ្នកខ្លះៗ។ យើងប្រហែលចូលជ្រៅបន្តិចនៅចំនុចនេះ។ ខ្ញុំមិនរំពឹងថាអធិប្បាយ បង្រៀនឬគោលលទ្ធិនោះទេ ប៉ុន្តែខ្ញុំគ្រាន់តែសួរអ្នករឿងមួយ។

72 ព្រះយេស៊ូវ គឺជាព្រះបន្ទូល។ យើងដឹងហើយ។ ព្រះបន្ទូល បានថែងដូច្នោះ។ នៅយ៉ូហាន ជំពូកទី១ "កាលដើមដំបូងឡើយមានព្រះបន្ទូលហើយព្រះបន្ទូលគង់នៅជា មួយព្រះ ហើយព្រះបន្ទូលនោះគឺជាព្រះ។ ហើយព្រះបន្ទូលបានក្លាយជាសាច់ឈាមគង់នៅចំណោមយើង។" ទ្រង់នៅតែជាព្រះបន្ទូល។ បន្ទាប់មក នៅពេល ដែលទ្រង់អាចយល់ពីគំនិតរបស់ពួកគេ ពួកគេគួរតែដឹងថានោះគឺជាព្រះបន្ទូល ព្រោះព្រះបន្ទូលនៃព្រះបានមានបន្ទូលថា នោះជាអ្វីដែលត្រូវធ្វើ។ ទ្រង់គឺជាព្យាការី។

73 ឥឡូវ សូមកត់ចំណាំ យើងបានដឹងថា ទ្រង់បានប្រសូត្រមក បានប្រហែលដប់ពីរឆ្នាំ ទ្រង់បានយាងទៅពិធីពោងឧបោសថ។ ហើយពួកគេបានទៅចូលរួមបុណ្យរំលង។ នៅតាមផ្លូវ ពេលត្រលប់មកវិញ ពួកគេត្រូវធ្វើដំណើរអស់រយះពេល

បីថ្ងៃ ហើយពួកគេបានបាត់ព្រះយេស៊ូវ ដោយមិនដឹងខ្លួន គាត់បានគិតស្មានថា ព្រះយេស៊ូវបានធ្វើដំណើរជាមួយពួកគេ។

74 យើងអាចរៀន ពីមេរៀនមួយនៃការនោះ។ វាសំខាន់ណាស់សម្រាប់ថ្ងៃនេះ ឥឡូវ អ្នកជាពួកមេតូឌីស បាបទីស្ទ ព្រីសប៊ីធើរៀន លូធើរៀន កាតូលិក អ្នកជាអ្វីក៏ដោយ អ្នកឃើញទេ អ្នកគឺកំពុងធ្វើការនោះដូចគ្នា។ អ្នកបានទទួល ព្រោះតែវេស្លីមានការផុសផុលដ៏អស្ចារ្យ លូធើរៀនមានការផុសផុលដ៏អស្ចារ្យ ឬពេនតេកុស្ដមានការផុសផុលដ៏អស្ចារ្យដែរ គឺយល់ដូច្នោះ ទ្រង់គង់ក្នុងចំណោមមនុស្ស ដែលពេលខ្លះទ្រង់មិនគង់នៅទីនោះក៏ដោយ។

75 ពួកគេបានស្វែងរកទ្រង់។ តើពួកគេរកទ្រង់នៅទីណា? ពួកគេបានទុកទ្រង់ចោលនៅទីណា នៅយេរ៉ូសាឡឹមឬ។ ហើយនៅពេលដែលពួកគេ រកទ្រង់ឃើញ តើទ្រង់កំពុងតែធ្វើអ្វី? ក្មេងប្រុសម្នាក់អាយុដប់ពីរឆ្នាំ ប្រហែលជាមិនទាន់ បានចូលរៀនផង ហើយចេះអ្វីមិនច្រើនជាងអ្វី ដែលម្ដាយបានបង្រៀននោះទេ ទ្រង់គឺគង់នៅក្នុងព្រះវិហារ កំពុងជជែកជាមួយនឹងពួកសម្ដេចសង្ឃ អំពីព្រះបន្ទូល នៃព្រះ។ ហើយពួកគេបានភ្ញាក់ផ្អើលពីប្រាជ្ញារបស់ក្មេងនេះ។ ហេតុអី? ទ្រង់គឺជាព្រះបន្ទូល។ ឥឡូវ ចូរមើល។

76 ហើយឥឡូវនេះមិនមែន មិនគោរពអ្នកទេ ដែលពួកកាតូលិកហៅនាងម៉ារាថាជាមាតានៃព្រះប៉ុន្តែសូមឲ្យបង្ហាញនូវបញ្ហាខ្លះនៅត្រង់នេះ។ បើសិនជាព្រះវិហារបានសាងសង់ដោយនាងម៉ារា តើវានឹងមានអ្វីកើតឡើង។ ឥឡូវ នាងបានមកដល់ទីនេះហើយបាននិយាយថា "អូ ឪពុករបស់អ្នកនិងខ្ញុំ ស្វែងរកអ្នកទាំងទឹកភ្នែក។" ចូរមើលឃ្លានោះ នាងបន្ទោសទីបន្ទាល់ដោយខ្លួននាងផ្ទាល់។ នាងបាននិយាយថា "បិតារបស់អ្នកនិងខ្ញុំ ស្វែងរកអ្នកទាំងទឹកភ្នែក។"

77 ចូរមើលព្រះបន្ទូលនោះ។ ទ្រង់គឺជាព្រះបន្ទូល។ ទ្រង់បានមានបន្ទូលថា "តើអ្នកមិនដឹងទេឬថា ខ្ញុំត្រូវធ្វើកិច្ចការបិតារបស់ខ្ញុំ?" មើលព្រះបន្ទូលកែតម្រូវកំហុស។ នៅទីនោះចំពោះមុខពួកសង្ឃនាងបានបំផ្លាញទីបន្ទាល់របស់នាង។ និយាយ នាងនឹងប្រសូត្រ ដោយព្រះវិញ្ញាណបរិសុទ្ធ ហើយនៅទីនេះ នាងនិយាយថា យ៉ូសែប គឺជា "ឪពុក" របស់ទ្រង់។ ឃើញទេ ព្រះបន្ទូលចាប់បានយ៉ាងលឿន? ទ្រង់គឺជាព្រះបន្ទូល។ ឥឡូវ អ្នកដឹងទេ ក្មេងប្រុសអាយុ១២ឆ្នាំមិនអាចធ្វើបែបនោះបានទេ។ ទ្រង់គឺជាព្រះបន្ទូល។ ទ្រង់គឺជាសំលេងដែលមានបន្ទូលរួចហើយនៅ

សម័យនោះ ដូច្នេះការបង្ហាញលក្ខណៈពិសេសរបស់ព្រះគឺនៅក្នុងព្រះគ្រីស្ទ។ ទ្រង់កែតម្រូវនូវកំហុស។ ទ្រង់មានបន្ទូល...

ពួកគេនិយាយ "ហេតុអ្វី យើងគឺជាសាវករបស់ម៉ូសេ។" ឃើញទេ?

78 ទ្រង់មានបន្ទូលថា "បើអ្នកជាសិស្សរបស់ម៉ូសេ អ្នកគួរតែស្គាល់ខ្ញុំ។ គាត់បានសរសេរពីខ្ញុំ។ ម៉ូសេបាននិយាយថា 'ព្រះជាម្ចាស់ជាព្រះនៃអ្នកនិងលើកព្យាការីម្នាក់ដូចខ្ញុំឡើង។' អ្នកគួរតែស្គាល់ខ្ញុំបើសិនជាអ្នកបានស្គាល់ម៉ូសេ។"

79 ហើយ អ្នកឃើញទេ ព្រះបន្ទូលបានកែប្រែរាល់កំហុសបានពីមួយថ្ងៃទៅមួយថ្ងៃ។ ប៉ុន្តែ មនុស្សមិនចូលចិត្តជឿវាទេ។ ពួកគេគ្រាន់តែកាន់ខ្ជាប់អ្វីដដែលៗ។

80 ប៉ុន្តែ ព្រះយេស៊ូវបានកែតម្រូវម្ដាយរបស់ទ្រង់។ ហើយមាតារបស់ទ្រង់ បានធ្វើអោយមានកំហុស ព្រោះនាងបាននិយាយរួចហើយអំពី កូនដែលនឹងចាប់កំណើតដោយព្រះវិញ្ញាណបរិសុទ្ធក្នុងផ្ទៃរបស់នាង ហើយនាងបានធ្វើទីបន្ទាល់រួចហើយ នាងបាននិយាយទៅ យ៉ូសែបថា យ៉ូសែបជា "ឪពុក" គឺជាឪពុករបស់—របស់ព្រះយេស៊ូវ។ ឥឡូវ បើ—បើយ៉ូសែប...

81 បើសិនជា ទ្រង់ជាកូនរបស់យ៉ូសែប ហើយប្រសិនបើទ្រង់កំពុងធ្វើកិច្ចការរបស់បិតាទ្រង់ ទ្រង់នឹងក្លាយជាជាងឈើដូចឪពុកទ្រង់ដែរ។

82 ប៉ុន្តែទ្រង់គឺបានធ្វើកិច្ចការបិតាទ្រង់ នៅក្នុងព្រះវិហារ ស្ដីបន្ទោសទៅអង្គការទាំងនោះ។ ឃើញទេ? ទ្រង់ធ្វើកិច្ចការបិតាទ្រង់ក្នុងពេលអាយុទើបតែ ដប់ពីរឆ្នាំប៉ុណ្ណោះ។ "តើអ្នកមិនដឹងទេឬថា ខ្ញុំត្រូវធ្វើកិច្ចការបិតារបស់ខ្ញុំ?"

83 តើអ្នកបានចំណាំទេ នៅពេលដែលព្រះយេស៊ូវ ត្រូវអារក្សល្បួង? លក្ខណៈពិសេសទ្រង់គឺនៅត្រង់នោះ នៅពេលដែលទ្រង់ជួបសេចក្ដីល្បួង ទទួលថាទ្រង់ជាព្រះ ព្រោះទ្រង់បាននៅជាប់ជាមួយនឹងព្រះបន្ទូល។ ឃើញទេ? "បានចែងមកដូច្នេះ" និយាយទៅកាន់សាតាំង។

ព្រះយេស៊ូវមានបន្ទូលថា "ក៏បានចែងទុកមកដូច្នេះ" ចូរឲ្យនៅជាប់ជាមួយព្រះបន្ទូល។

84 "ព្រះជាម្ចាស់ ពីដើម" សូមយើងអាននៅទីនេះ។ "ព្រះជាម្ចាស់ កាលពីដើម" នោះជាពេលដ៏យូរមកហើយ "ជាច្រើនដង ច្រើនបែប" តាមមធ្យោបាយជាច្រើន "ទ្រង់បង្ហាញអង្គទ្រង់ទៅកាន់ហោរាតាមរយៈនិមិត្ត។" នោះគឺជា លក្ខណៈពិសេស

ព្យាការីរបស់ទ្រង់ ទៅពេលដែលទាយមកនោះវានឹងកើតឡើងមែន។ ឥឡូវ ចរិកលក្ខណៈគាត់ គឺបង្ហាញថាព្រះគង់នៅជាមួយគាត់។ បន្ទាប់មក ទ្រង់បានឲ្យសិទ្ធិគាត់ក្នុងការបកស្រាយព្រះបន្ទូលនៅសម័យ នោះ ពីព្រោះ "ព្រះបន្ទូល របស់ព្រះបានមកដល់ពួកហោរា" លក្ខណៈ របស់ព្យាការី គឺការទាយទុកមុន។

85 ព្រះគម្ពីបានចែងថា "បើមានការមួយ ហើយគាត់ បាននិយាយ ហើយអ្នកបានលឺគាត់និយាយតែបើវាមិនកើតឡើងទេកុំជឿគាត់ កុំខ្លាចគាត់ ប៉ុន្តែខ្ញុំ...នោះ—នោះពាក្យរបស់ខ្ញុំមិននៅក្នុងគាត់ទេ តែបើវាកើតឡើងមែននោះពាក្យរបស់ខ្ញុំគឺនៅក្នុងគាត់។" នោះជាការបង្ហាញគាត់។ នោះជាលក្ខណៈពិសេសរបស់ព្យាការី។

86 ឥឡូវនេះ ព្រះជាម្ចាស់ កាលពីដើម នោះជារបៀបដែលទ្រង់បង្ហាញអង្គទ្រង់ដើម្បីសម្គាល់អង្គទ្រង់ផ្ទាល់ទៅកាន់មនុស្សការនិយាយទៅកាន់មនុស្សម្នាក់ ដែលត្រូវបានហៅថាជាព្យាការី។ ឥឡូវ ព្រះគម្ពីរបានចែងដូច្នោះ "ឯព្រះ ដែលពីដើម ទ្រង់មានព្រះបន្ទូលនឹងពួកឰយុកោ ដោយពួកហោរា ជាច្រើនដងច្រើនបែប។"

87 យើងនឹងអាននៅ ពេត្រុសខ្សែទីពីដែរ ពេញមួយជំពូកតែម្តង។ "អ្នកចាស់ទុំ បានផ្លាស់ប្តូរ ដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសរសេរនៅក្នុង ព្រះគម្ពីរ។" ពួកគេគឺជា ព្យាការី។ ព្រះបន្ទូលបានមកដល់ពួកគេ ហើយពួកគេបានសរសេរឡើង ដោយមានការបណ្តាលចិត្ត។ ទីមួយ ពួកគេស្គាល់ខ្លួនពួកគេថាជា ព្យាការី បន្ទាប់មក ពួកគេ—ពួកគេសរសេរព្រះបន្ទូល នៃការបណ្តាលចិត្ត ហើយពួកគេមានការបកស្រាយដោយការបើកសំដែងពីព្រះ ព្រោះព្រះគង់ នៅក្នុងមនុស្ស។

88 នោះហើយជាវិធី ដែលទ្រង់បង្ហាញអង្គទ្រង់ ក្នុងលក្ខណៈពិសេសនៃអត្តសញ្ញាណរបស់ទ្រង់ និមិត្តរបស់ពួកគេត្រូវតែជាការពិត នោះគឺលក្ខណៈពិសេសរបស់ព្រះក្នុងពួក គេ បង្ហាញអង្គទ្រង់ឲ្យស្គាល់ក្នុងចំណោមពួកគេ។

89 ឥឡូវ នោះជាវិធីតែមួយដែលទ្រង់នៅក្នុងព្រះគ្រីស្ទ។ ព្យាការីគ្រាន់តែជាកន្លែងតូចមួយប៉ុណ្ណោះ។ ព្រះគ្រីស្ទគឺជាភាពពេញលេញរបស់ព្រះ។ ហើយព្រះនៅក្នុងព្រះគ្រីស្ទ។ គឺផ្សះផ្សាពិភពលោកទៅកាន់ទ្រង់ខ្លួនឯង។ ហើយលក្ខណៈពិសេសបញ្ជាក់ថាទ្រង់ជាអ្វី តាំងពីដើមទ្រង់មានព្រះបន្ទូលថា "បើសិនជា ខ្ញុំមិនបានធ្វើការរបស់ព្រះវបិតាខ្ញុំទេ ដូច្នេះ កុំជឿខ្ញុំ។ បើសិនជាខ្ញុំ គ្មានលក្ខណៈ របស់ព្រះវបិតាខ្ញុំទេ សូមកុំជឿខ្ញុំ កុំជឿពាក្យ របស់ខ្ញុំអោយសោះ។ បើសិនជាខ្ញុំ គ្មានលក្ខណៈរបស់ព្រះវបិតាខ្ញុំនៅក្នុងខ្លួនខ្ញុំ កុំជឿពាក្យ របស់ខ្ញុំអោយសោះ។"

90 ឥឡូវលក្ខណៈពិសេសរបស់ទ្រង់ មិនដែលផ្លាស់ប្តូរឡើយ។ ព្រះមិនអាចផ្លាស់ប្តូរលក្ខណៈរបស់ទ្រង់ទេ—ដូចជា ជា—ចៀមមិនអាចផ្លាស់ប្តូរ លក្ខណៈរបស់វាបានទេ ឬអ្វីផ្សេងទៀត មិនអាចផ្លាស់ប្តូរលក្ខណៈពិសេសរបស់វាបានទេ។ ព្រោះដរាបណាវាដូចដើម វានៅតែដូចដើមដដែល។ ហើយ បើសិនជាអ្នកផ្លាស់ប្តូរវាត្រូវតែផ្លាស់ប្តូរតាំងពីដើម។

91 វាដូចជាអ្នកយក—ជ្រូកមួយក្បាលហើយលាងវា—ហើយលាបក្រចកជើងដូចជាស្ត្រីធ្វើនិងដាក់ក្រែមបន្តិច ស្លៀកពាក់ឲ្យស្អាត។ ត្រឡប់ទៅវិញ វានិងតម្រង់ទៅភក់គឺភក់ម្តងទៀត។ ហេតុអី? វាគឺជាជ្រូកតែប៉ុណ្ណឹង។ ប៉ុន្តែ ប៉ុន្តែអ្នកដឹងទេ អ្នកមិនអាចធ្វើបានទេ...

92 កូនចៀមមិនធ្វើដូច្នោះទេ។ វាមិនទៅកាន់ភក់នោះទេ។ វាគ្មានអ្វីធ្វើជាមួយការ នោះទេ។ នោះជាលក្ខណៈធម្មជាតិរបស់វា។ ឃើញទេ? អ្នកអាចស្លៀកពាក់ឲ្យ វានូវសំលៀកបំពាក់ដូចគ្នា ប៉ុន្តែច្បាស់ណាស់ វាច្បាស់ណាស់ថាវាមិនអាចទេ។ ខាងក្រៅមិនជាបញ្ហានោះទេ វាគឺខាងក្នុង។ ឥឡូវនេះព្រះគឺជាប្រភពនៃជីវិតទាំងអស់...

93 សូមកុំរបូតវា។ ខ្ញុំព្យាយាមអស់ពីចិត្តដើម្បីនាំអ្នកទៅមើលអ្វីមួយ។ ឃើញទេ? គឺដើម្បីឲ្យអ្នកល្អទេសម្លាញ់។ វាគឺតំណាង—របស់អ្នក។ ឃើញទេ?

94 ខ្ញុំមក មិនគ្រាន់តែសម្រាប់អោយអ្នកឃើញទេ។ ខ្ញុំមិនមកទីនេះ ព្រោះគ្មានកន្លែង ទៅនោះទេ។ ខ្ញុំមកទីនេះ ព្រោះខ្ញុំចង់មក។ ខ្ញុំ មានអារម្មណ៍ថា ព័ន្ធកិច្ចដែលព្រះបានឲ្យខ្ញុំត្រូវតែបង្ហាញទៅកាន់មនុស្សនៅទីនេះ ហើយខ្ញុំព្យាយាម នាំអ្នកឲ្យឃើញថាព្រះពិតជាអ្វីឥឡូវ។ ទ្រង់គឺជាព្រះបន្ទូលសន្យា។ ទ្រង់នៅតែជាព្រះបន្ទូលជានិច្ច ហើយទ្រង់បង្ហាញអង្គទ្រង់តាមរយៈលក្ខណៈពិសេសដែលទ្រង់បានសន្យា។ លក្ខណៈជាក់លាក់ អាចលេចឡើងក្នុងពេលវេលាច្បាស់លាស់ នោះគឺក្នុងព្រះបន្ទូល ហើយលក្ខណៈពិសេសរបស់មនុស្សនេះ នឹងលេចឡើងបង្ហាញឲ្យស្គាល់ថាជាមនុស្សនោះ។

95 នោះ ជាហេតុផលដែលព្រះយេស៊ូវត្រូវធ្វើជាអ្នកដែលទ្រង់ជា។ ពួកគេ គួរតែធ្លាប់ឃើញវា។ គ្មានអ្វីឆ្ងល់ទេពួកគេបានខ្វាក់។ នោះគឺ...និយាយទោះបីជាទ្រង់ធ្វើការអស្ចារ្យច្រើនយ៉ាងណា ប៉ុន្តែពួកគេនៅតែមិនជឿទ្រង់ ព្រោះគម្ពីរអេសាយថែងថា "ពួកគេមានភ្នែក តែមើលមិនឃើញ ហើយមានត្រចៀក តែស្តាប់មិនលឺ។"

ឃើញទេ? គ្រប់សម័យកាល មិនមែនតែសម័យកាលរបស់ទ្រង់នោះទេប៉ុន្តែគ្រប់សម័យកាល ដោយរបៀបណា "ព្រះជាម្ចាស់ កាលពីដើម ជាច្រើនដង ច្រើនបែប" នៅតែពួកគេមិនយល់។

96 ឥឡូវលក្ខណៈពិសេសរបស់ទ្រង់ មិនដែលប្តូរនោះទេ។ វានៅតែដដែល។ ឥឡូវ សូមចងចាំពីលក្ខណៈពិសេសរបស់ទ្រង់លក្ខណៈពិសេសរបស់ព្រះមិនអាចបាត់បង់ឡើយ។ បើមិនដូច្នេះទេ នោះព្រះជាម្ចាស់នឹង បញ្ចប់ទីសម្គាល់នោះ។ ហើយព្រះគម្ពីរហេព្រើជំពូក១៣ខទី៨ចែងថា "ដ្បិតព្រះយេស៊ូវគ្រីស្ទ ទ្រង់នៅតែដដែល គឺពីថ្ងៃម្សិលមិញ ថ្ងៃនេះ ហើយទៅដល់អស់កល្បទៅ។" ដូច្នេះហើយបានជាទ្រង់ជា ព្រះមិនប្រែប្រួលទេ។ លក្ខណៈពិសេសទ្រង់ពីដើមយ៉ាងម៉េចគឺនៅតែដដែល។ គ្រប់វិធីដែលទ្រង់ធ្វើ ពេលណាដែលទ្រង់បានធ្វើ គឺទ្រង់ធ្វើដូចគ្នាគ្រប់ពេល។ បើសិនជា ទ្រង់មិនធ្វើដូច្នោះទេ នោះទ្រង់នឹងមានការផ្លាស់ប្តូរ យល់ហើយលក្ខណៈពិសេសរបស់ទ្រង់មិនអាចបង្ហាញអ្វីដែលមិនមកពីព្រះឡើយ។ ឃើញទេ? ដូច្នេះ យើងមិន អាចដឹងកន្លែងណាទេ...

97 ដូចជា ប៉ុលបាននិយាយថា បើសិនជាត្រែ បញ្ចេញសំឡេង មិនច្បាស់ទេ នរណានឹងដឹងពីការធ្វើសឹកសង្គ្រាមនោះ បើសិនជាត្រែ បញ្ចេញ សំឡេងមិនច្បាស់? ដូច្នេះ បើសិនជា ត្រែនោះត្រូវមានសំឡេង "ថយចុះ" អ្វីដែលយើងត្រូវធ្វើគឺដកថយ ។ ហើយបើសិនជា វាមានសំឡេង "ចូល" អ្វីដែលយើងត្រូវធ្វើគឺចូលដែរ។ ប៉ុន្តែ តើអ្វីទៅជាត្រែ? វាជាព្រះបន្ទូលនៃព្រះជាម្ចាស់។ វាសម្គាល់ថាជាព្រះ ទោះបីជា—ទោះបីជា "ទៅមុខ អង្គុយចុះ ដកថយ លើកអាវុធ" ជាអ្វីក៏ដោយ។ នោះជាសម្លេងត្រែរបស់ព្រះជាម្ចាស់។

98 ហើយសម្លេងមិនច្បាស់ នៅពេលដែលព្រះគម្ពីរបានចែងច្បាស់នូវអ្វីដែលនឹងកើតឡើង មានអ្នកខ្លះ និយាយថា "អូ វាកើតនៅថ្ងៃនោះទេ។" នោះជាសម្លេង ដែលមិនប្រាកដ។ ហើយអ្នលនឹងមិនដឹងថានឹងធ្វើអ្វីឡើយ។

99 ព្រះយេស៊ូវមានបន្ទូលថា "ខ្ញុំមានអំណាចដាក់ជីវិតរបស់ខ្ញុំចុះ ក៏អាចលើកឡើងវិញបានដែរ។" មិនមានសំលេងមិនច្បាស់ទេនៅទីនោះ។

100 ស្ត្រីម្នាក់ បាននិយាយថា "យើងដឹងថាព្រះមេស្ស៊ីនឹងយាងមក ហើយពេលទ្រង់យាងមកទ្រង់នឹងប្រាប់យើងនូវអ្វីដែលទ្រង់បានធ្វើ។"

101 ទ្រង់មានបន្ទូលថា "ខ្ញុំជាទ្រង់" មិនមានសំឡេងមិនច្បាស់ទេ។ "ខ្ញុំគឺជាទ្រង់" អូហូ! អាម៉ែន។

ពួកគេ និយាយថា "ពួកឰយុកោរបស់យើង បរិភោគនំម៉ានានៅរហោស្ថាន។"

102 ទ្រង់មានបន្ទូលថា "ពួកគេគ្រប់គ្នា គឺស្លាប់។" ទ្រង់មានបន្ទូលថា "ប៉ុន្តែខ្ញុំជានំប៉័ងជីវិត ដែលមកពីព្រះជាម្ចាស់ ដែលគង់នៅស្ថាន។" មិនមានសំលេងមិនពិតទេ។ "ខ្ញុំគឺជាដើមឈើជីវិត ដែលមកពីសួនអេដែន។" គ្មានទេ មិនមាន សំឡេងមិនពិតនោះទេ។ ច្បាស់ណាស់គ្មានទេ។ គ្មានអ្វីដែលមិនច្បាស់ទាល់តែសោះ។ ទ្រង់គឺច្បាស់លាស់គ្រប់ការទាំងអស់ដែលទ្រង់បានធ្វើ។

103 ព្រះគម្ពីរមិនបានផ្តល់សំឡេងមិនពិតនោះទេ។ វាសម្គាល់ ពីលក្ខណៈពិសេសព្រះជាម្ចាស់ នៅក្នុងសំឡេងនោះ។

104 ព្រះយេស៊ូវ មានព្រះបន្ទូលនៅក្នុង យ៉ូហាន ជំពូក១០ ខទី៣៧ថា "បើសិនជាខ្ញុំមិនបានធ្វើការ របស់ព្រះវបិតាខ្ញុំទេ តើ...ហើយខ្ញុំគ្មានលក្ខណៈនៃព្រះវបិតានោះកុំជឿខ្ញុំឡើយ។ ពួកគេគឺតែមួយ ពួកគេសម្គាល់លក្ខណៈពិសេសនៅក្នុងខ្ញុំ។ លក្ខណៈពិសេសរបស់ទ្រង់។"

105 ពីព្រោះ ព្រះវរបិតាគឺជាព្រះបន្ទូល "នៅដើមដំបូងឡើយមាន ព្រះបន្ទូល ហើយព្រះបន្ទូលនោះក៏គង់ជាមួយនឹងព្រះហើយព្រះបន្ទូល គឺជាព្រះ" ហើយលក្ខណៈរបស់ព្រះគឺបង្ហាញតាមការសន្យានៅសម័យនោះ។

106 ឥឡូវបើសិនជា ទ្រង់គង់នៅសម័យលោកម៉ូសេ វាមិនអាចបានទេ។ ហើយបើសិនជាលោកម៉ូសេរស់នៅសម័យរបស់ទ្រង់វិញវាក៏មិអាចបានដែរ។ បើសិនជាទ្រង់គង់នៅសម័យណូអេវាមិនអាចបានទេ ឬក៏ណូអេរស់នៅសម័យរបស់ទ្រង់ ក៏មិនអាចបានដែរ។ ណូអេ បានទស្សន៍ទាយនៅសម័យនោះហើយចរិកលក្ខណៈរបស់គាត់និងអ្វីដែលគាត់បានធ្វើគឺបង្ហាញពីព្រះបន្ទូលព្រះ។ ម៉ូសេក៏បាន ធ្វើដូចគ្នាដែរ។

107 ហើយព្រះយេស៊ូវបានយាងមក ហើយព្រះបន្ទូលដែលបានសន្យា ពីសម័យនោះគឺត្រូវបាន សម្គាល់លក្ខណៈនៅក្នុងព្រះគ្រីស្ទ ដោយលក្ខណៈនៃព្រះបន្ទូលដែលជាព្រះ អាម៉ែន។

108 ការចាក់បង្ហូរនៃព្រះវិញ្ញាណបរិសុទ្ធ នៅថ្ងៃចុងបញ្ចប់ ទៅលើមនុស្សធម្មតា ត្រូវបានសម្គាល់លក្ខណៈរបស់ព្រះនៅក្នុងមនុស្ស។ ទ្រង់បានសន្យាវា។ នោះគឺជាព្រះបន្ទូល។ ទ្រង់មានបន្ទូល ទ្រង់នឹងធ្វើវាបាន។ គ្មាននរណាម្នាក់យកវាបានទេ។ ទ្រង់មានបន្ទូល ទ្រង់នឹងអាចធ្វើវាបាន។

109 ដូច្នេះ គ្រប់ការទាំងអស់ ដែលទ្រង់បានសន្យា នោះជាអ្វីដែលទ្រង់បានធ្វើ។ នោះគឺសម្គាល់លក្ខណៈរបស់ទ្រង់។ ត្រូវហើយ។ "កុំជឿអោយសោះ កុំជឿការប្រ កាសរបស់ខ្ញុំអី បើសិនជាការដែលខ្ញុំ បានធ្វើមិនមែនតាមព្រះទ័យរបស់ព្រះជាម្ចាស់។"

110 ឥឡូវសូមកត់ចំណាំ នៅយ៉ូហាន ជំពូក១៤ ខទី១២ "អ្នកណាដែលជឿដល់ខ្ញុំ" ទ្រង់មានបន្ទូលថា "មានអត្តសញ្ញាណរបស់ខ្ញុំ មានលក្ខណៈរបស់ខ្ញុំ។ អ្នក ណាដែលជឿដល់ខ្ញុំ ការងារដែលខ្ញុំធ្វើ នោះគេនឹងធ្វើដែរ។" នោះបញ្ជាក់យ៉ាងច្បាស់ថា លក្ខណៈរបស់ព្រះគ្រីស្ទ គឺនៅក្នុងគាត់បង្ហាញ លក្ខណៈរបស់ទ្រង់។ អាម៉ែន។

111 ខ្ញុំមានអារម្មណ៍ជាសាសនាឥឡូវបើសិនជាខ្ញុំមានសំឡេងស្អក។ ត្រូវហើយ។ អូ ខ្ញុំអើយ! ឃើញទេ វាគ្មានបញ្ហាទេការនោះ! ជីវិតរបស់ទ្រង់! "អ្នកណាដែលជឿដល់ខ្ញុំការងារដែលខ្ញុំធ្វើ នោះនឹងធ្វើបានដូចខ្ញុំដែរ។" ឃើញទេ នោះគឺជាការបង្ហាញពីលក្ខណៈពិសេស។

112 ដូចដែលទ្រង់បានមានបន្ទូលថា "បើសិនជាលក្ខណៈរបស់ខ្ញុំ មិនបានបញ្ជាក់ពីខ្ញុំទេ ព្រះនៅ—ក្នុងខ្ញុំ ដូច្នេះ(គាត់)កុំជឿទ្រង់។" ឥឡូវទ្រង់ក៏មានបន្ទូលថាទ្រង់នឹងបង្ហាញនៅក្នុងនោះ។ ហើយបន្ទាប់មក បើសិនជា មិនស្គាល់ខ្លួនទ្រង់ផ្ទាល់ទេ នោះគាត់មិនមែនជាអ្វីដែលបាននិយាយឡើយ។

113 ហើយនៅថ្ងៃនេះ បើសិនជា ព្រះគ្រីស្ទ មិនស្គាល់អង្គទ្រង់ផ្ទាល់ទេ លក្ខណៈនៃ ព្រះគ្រីស្ទ ដែលគង់ក្នុងយើង គឺជាព្រះគ្រីស្ទ ជឿព្រះបន្ទូល...ព្រះយេស៊ូវគឺជា ព្រះបន្ទូល ដូច្នេះ ទ្រង់ត្រូវតែជឿដល់ព្រះបន្ទូល។ ហើយ តើយើង អាចនិយាយថានៅក្នុងព្រះគ្រីស្ទដោយរបៀបណាបើយើងបដិសេធព្រះបន្ទូលណាមួយនៅក្នុងព្រះគម្ពីរ? ព្រះវិញ្ញាណបរិសុទ្ធនៃព្រះគ្រីស្ទគឺជាព្រះ នៅក្នុងអ្នក ហើយវាកំណត់សញ្ញា គ្រប់ទាំងការសន្យា ទាំងអស់ដោយពាក្យ "អាម៉ែន។" ព្រះគម្ពីរ បានចែងថា "ទីសម្គាល់ ទាំងអស់នេះ នឹងនៅជាមួយ អស់អ្នកដែលជឿ។" ព្រះវិញ្ញាណរបស់ ព្រះបានមានបន្ទូលថា "អាម៉ែន។" ឃើញទេ?

114 ម្នាក់ក្នុងចំណោមពួកគេ កុំនិយាយ "ទេ វាសំរាប់សម័យកាលផ្សេងទៀតនោះគឺសំរាប់តែពួកសាវកប៉ុណ្ណោះ។"

115 "ចូរចេញទៅលោកិយហើយផ្សាយដំណឹងល្អទៅកាន់គ្រប់មនុស្សទាំងអស់។ អស់អ្នកណា នៅលើពិភពលោកដែលជឿ ទីសម្គាល់នេះនឹងតាមពួកគេដូចគ្នា។" "ដូចម្សិលមិញ ថ្ងៃនេះ នឹងជារៀងរហូត" លក្ខណៈពិសេសត្រូវបានសម្គាល់។

116 នោះគឺនៅហេព្រើ ជំពូក១ ខទី១ "ឯព្រះដែលពីដើម ទ្រង់មានបន្ទូលនិងពួកឰយុកោដោយពួកហោរា" លក្ខណៈសម្គាល់នៃព្រះគ្រីស្ទ បានរស់ឡើងវិញនៅថ្ងៃនេះ ដោយលក្ខណៈសម្គាល់ដូចគ្នាដែលទ្រង់បានធ្វើនៅពីដើម។ តើអ្នកយល់ទេ? ព្រះជាម្ចាស់មិនដែលផ្លាស់ប្តូរឡើយ។

117 នៅក្នុងព្រះគម្ពីរសញ្ញាចាស់ នៅពេលដែលអ្នកយល់សុបិន្ត ហើយនៅទីនោះ អត់មានព្យាការី ថាតើសុបិន្តនោះត្រូវ ឬខុស ពួកគេបានស្វែង រកវិធីផ្សេងៗ។ ពួកគេបានយកអ្នកដែលយល់សុបិន្តនោះនាំគាត់ទៅកាន់ព្រះវិហារ។ ប្រដាប់បាំងទ្រូងអ៊ីរ៉ុនជាសម្តេចសង្ឃ ដែលព្យួរនៅទីនោះ។ ហើយអ្នកយល់សប្តនិង ប្រាប់ពីសុបិន្តនេះ។ មិនថាវាពិរោះប៉ុណា វាពិតប៉ុណាតែបើមិនមានពន្លឺជះ ទៅលើថ្មទាំងនោះ ដែលហៅថាយូរីមធូមីម (អ្នកអានព្រះគម្ពីរបានយល់) បន្ទាប់មក ខ្ញុំមិនខ្វល់ថាវាជាសំឡេងពិតឬអត់វាមិនអាចទេ។ ភាពអស្ចារ្យរបស់ព្រះ លក្ខណៈរបស់ព្រះ ត្រូវតែសម្តែងចេញតាមរយៈលក្ខណៈពិសេសដ៏អស្ចារ្យរបស់ទ្រង់ ដើម្បីបង្ហាញថាទ្រង់សម្តែងអង្គទ្រង់ផ្ទាល់នៅក្នុងរាជសារ។ អាម៉ែន។

118 ខ្ញុំនិយាយពាក្យដដែលនៅយប់នេះ។ យូរីម ធូមីមចាស់បានផុតបាត់ហើយ ប៉ុន្តែ ព្រះបន្ទូលរបស់ទ្រង់នៅតែ សម្គាល់ពី លក្ខណៈនៃព្រះជាម្ចាស់ដដែល សេចក្តីសន្យា នៃពេលវេលាដែលយើងរស់នៅ។ គឺមានការសម្តែងពីចរិកលក្ខណៈរបស់ព្រះ តាមរយៈសេចក្តីសន្យាពេលវេលាដែលយើងរស់នៅ។

119 នោះ ជាការដែលធ្វើអោយទ្រង់នៅតែដដែល។ "នៅកាលពីដើម" ចូរមើល "ក្នុងរបៀបផ្សេងគ្នា ទ្រង់មានបន្ទូលទៅពួកឰយុកោតាមរយៈព្យាការី។" "ហើយបញ្ញាត្តិនិងព្យាការី រហូតដល់យ៉ូហាន តាំងពី នគរស្ថានសួគ៌។" ចំណាំ "ប៉ុន្តែនៅក្នុងថ្ងៃចុងបញ្ចប់នេះ" ព្រះបន្ទូលគឺនៅតែដដែល ទ្រង់បានធ្វើ "តាមរយៈបុត្រារបស់ទ្រង់ព្រះយេស៊ូវគ្រីស្ទ។" "ព្រះជាម្ចាស់ កាលពីដើម របៀបផ្សេង មាន បន្ទូលទៅកាន់ពួកឰយុកោតាមរយៈព្យាការីដែរនៅក្នុងថ្ងៃក្រោយ" ធ្វើការដូចគ្នា "បាន

និយាយទៅកាន់មនុស្ស (ពួកឰយុកោ) តាមរយៈព្រះយេស៊ូវគ្រីស្ទដែរ។” បានលើក ទ្រង់ឡើងវិញពីសេក្តីស្លាប់ ទ្រង់គង់ក្នុងយើង និងសម្តែងអង្គទ្រង់ផ្ទាល់ និងប្រាប់យើងជាមុន ទ្រង់ជ្រាបនៅគំនិតក្នុងចិត្តរបស់យើងម្នាក់ៗ។ ព្រះយេស៊ូវគ្រីស្ទគឺដូចកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូតអស់កល្ប! “ព្រះជាម្ចាស់ កាលពីដើម និងច្រើនដងច្រើនបែបមានបន្ទូទៅកាន់ពួកឰយុកោតាមរយៈហោរា ប៉ុន្តែនៅថ្ងៃចុងក្រោយនេះតាមរយៈព្រះយេស៊ូវគ្រីស្ទបុត្រារបស់ទ្រង់។” បទគម្ពីមិនអាច ធ្វើបាបឡើយ។ វាជាការពិត។

120 ដូចដែល ខ្ញុំបាននិយាយពីមុនអ៊ីចឹង ព្រះជាម្ចាស់មិនត្រូវការ នណារម្នាក់មកបកស្រាយពីព្រះបន្ទូលនេះនោះទេ។ ទ្រង់បកស្រាយព្រះបន្ទូលដោយខ្លួនឯង។ នៅពេលដែលទ្រង់មានបន្ទូល វានឹងកើតឡើង នោះជាការដែលទ្រង់ បកស្រាយ។ ឃើញទេ? ទ្រង់មិនត្រូវការអ្នកនិយាយថា “ល្អ ខ្ញុំជឿថា វាមាន ន័យ*ដូច្នេះ* ។” ទ្រង់បង្ហាញវាដោយ ការបកស្រាយព្រះបន្ទូលរបស់ទ្រង់។

121 ប្រសិនបើការសន្យានេះ គឺសម្រាប់ថ្ងៃនោះ! យើងមិនអាចរស់នៅក្នុងពន្លឺនៃ—នៃ—នៃលូធើបានទេ។ យើងមិនអាចរស់នៅក្នុងពន្លឺរបស់វេស្លេបានទេ។ យើងមិនអាចរស់នៅក្នុងពន្លឺទាំងនោះបានឡើយ។ យើងត្រូវតែរស់នៅក្នុងពន្លឺ ដែលទ្រង់បានសន្យាសម្រាប់ថ្ងៃនេះ។

122 តើនឹងមានអ្វីកើតឡើង ប្រសិនបើលោកម៉ូសេ ពេលដែលគាត់ធ្វើដំណើរទៅ ប្រទេសអេហ្ស៊ីប ហើយបាននិយាយថា “មែនហើយ យើងនឹងសង់ទូកដ៏ធំមួយ។ យើងនឹងបណ្តែតចេញពីប្រទេសនេះ។ តើទន្លេនីលនឹងមានជំនន់ឬ”? ពួកគេត្រឡប់ទៅមើលក្រាំងនោះម្តងទៀត នៅទីនោះ គ្មានសេចក្តីសន្យានោះទេ។ ត្រូវហើយ។ ប៉ុន្តែ អ្នកឃើញទេគាត់បានសម្តែងខ្លួនគាត់ថាជាហោរារបស់ព្រះ អ្វីដែលគាត់និយាយវាបានកើតឡើងមែន។ បន្ទាប់មកពួកគេ ដឹងថាគាត់មានព្រះបន្ទូលរបស់ព្រះអម្ចាស់។ ព្រះចៅផារ៉ោនមានលំពែង ប៉ុន្តែលោកម៉ូសេមានព្រះបន្ទូល។ ដូច្នេះ នៅពេលដែលពួកគេទៅដល់សមុទ្រ លំពែង ទាំងអស់បានធ្លាក់ទៅក្នុងសមុទ្រ ហើយលោកម៉ូសេបាននាំពួក អ៊ីស្រាអែល ឆ្លងកាត់សមុទ្រនៅលើដីស្ងួត ដោយសារតែគាត់មានព្រះបន្ទូលនោះហើយគឺជាព្រះបន្ទូលនៃទ្រង់នៅពេលនោះ។ លោកម៉ូសេ គឺជាព្រះបន្ទូលដែលបាន សម្តែងសម្រាប់វេលានោះ។

លោកអេលីយ៉ា គឺជាព្រះបន្ទូលដែលបានសម្តែង សម្រាប់វេលានោះដែរ។

123 ព្រះគ្រីស្ទ គឺជាព្រះបន្ទូល ដែលបានសម្ដែង ហើយបានសម្រេចសេចក្ដីសន្យានោះ។ "នៅបន្តិចទៀត លោកិយ៍នឹងមិនឃើញខ្ញុំទៀតទេ ហើយអ្នកក៏ មិនឃើញខ្ញុំទៀតដែរ តែខ្ញុំនឹងនៅជាមួយអ្នក ទោះជាដល់ថ្ងៃចុងបញ្ចប់នៃ ពិភពលោកក៏ដោយ។ កិច្ចការដែលខ្ញុំបានធ្វើ អ្នកក៏នឹងធ្វើដូចគ្នាដែរ។" ទ្រង់បាន សន្យាការទាំងនេះ។ តើវាគឺជាអ្វី? វាជាលក្ខណៈរបស់ព្រះ ដែលបង្ហាញពី ព្រះបន្ទូលទ្រង់ដូចជាការដែលទ្រង់ បានធ្វើគ្រប់សម័យកាលទាំងអស់។

124 នៅម៉ាឡាគីជំពូក៤ ព្រះបានមានព្រះបន្ទូលថា "មុនថ្ងៃដ៏ធំគួរស្ញែងខ្លាច របស់ព្រះយេហូវ៉ាបានមកដល់ នោះអញនឹងចាត់ អេលីយ៉ា ហើយគាត់នឹង បង្វែរ សេចក្ដីជំនឿនៃកូនមកឯឪពុកម្ដងទៀតមុនពេលដែលថ្ងៃនោះមកដល់។" ទ្រង់បានសន្យាដូច្នោះ។

125 ព្រះយេស៊ូវមានបន្ទូលក្នុងលូកាជំពូក១៧ថា "ដូចដែល នៅក្នុងថ្ងៃនៃក្រុង សូដុមដែរដូច្នេះកូនមនុស្សក៏នឹងមកដែរជាពេលដែលកូនមនុស្សត្រូវបើកសម្ដែង។" នៅពេលដែលការបើកសម្ដែងនេះ ត្រូវបានលាតត្រដាង នៅក្នុងថ្ងៃនោះ នៅពេលដែលពិភពលោកមានភាពដូចក្រុងសូដុមដែរ តើវានឹងមានអ្វីកើតឡើង? លក្ខណៈពិសេសនៃបទគម្ពីរដែលបានកំណត់អត្តសញ្ញាណអង្គទ្រង់ ដោយចរិកលក្ខណៈរបស់ទ្រង់ លក្ខណៈពិសេសដែលទ្រង់តែងតែមានក្នុងទ្រង់ផ្ទាល់? ទ្រង់មិន ចេញឆ្ងាយពីលក្ខណៈនោះទេ។

126 នៅថ្ងៃចុងក្រោយ ទ្រង់នឹងបញ្ជាក់ តាមរយៈ ព្រះរាជបុត្រារបស់ទ្រង់។ សូមចំណាំរបៀបដែលព្រះធ្វើការទាំងនេះគឺទ្រង់—គឺទ្រង់មិនផ្លាស់ប្ដូរវិធីរបស់ទ្រង់ឡើយ វាដូចជាការដែលទ្រង់បាន...ទ្រង់មិនផ្លាស់ប្ដូរឡើយ។

127 បុរសទាំងបីនេះបាននិយាយទៅលោកអ័ប្រាហាំ ដូចដែលយើងបាន និយាយនៅទីនោះ នៅថ្ងៃនៃក្រុងសូដុមដែរ។

128 លោកអ័ប្រាហាំ ជាបុរសម្នាក់ដែលជឿដល់ព្រះជាម្ចាស់។ គាត់បានយកព្រះជាម្ចាស់ ទុកជាការសន្យារបស់គាត់។ សារ៉ាភរិយារបស់គាត់មានអាយុហុកសិបប្រាំឆ្នាំ លោកអ័ប្រាហាំមានអាយុចិតសិបប្រាំ នៅពេលដែលព្រះ បានត្រាស់ហៅគាត់។ ទ្រង់បានមានបន្ទូលថា ពួកគេនឹងមានកូនមួយ—មួយ! អ័ប្រាហាំនឹងមានកូនមួយ ដោយសារសារ៉ា។ វាស្ដាប់ទៅគួរឱ្យអស់សំណើច បន្តិច

ណាស់ ប៉ុន្តែខ្ញុំស្រមៃថា នាងបានទទួលការទាំងអស់នោះ នឹងបានត្រៀមខ្លួនជាស្រេចក្នុងការដែលពួកគេនឹងមានកូននេះ។

129 បន្ទាប់ពីម្ភៃប្រាំបីថ្ងៃដំបូង ហេតុអ្វី លោកអ័ប្រាហាំប្រហែលជានិយាយទៅសារ៉ាថា "តើអូនមានអារម្មណ៍យ៉ាងណា អូនសម្លាញ់?"

"មិនខុសគ្នាទេ។"

"សូមថ្វាយសិរីរុងរឿងដល់ព្រះទោះយ៉ាងណាយើងនឹងមាន។"

"តើអ្នកនឹងដឹង ដោយរបៀបណា?"

"ព្រះ ទ្រង់មានបន្ទូលដូច្នេះ។"

មួយឆ្នាំបានកន្លងផុតទៅ។ "តើអូនមាន អារម្មណ៍យ៉ាងណា អូនសម្លាញ់?"

"មិនខុសគ្នាទេ។"

"យើងនឹងមានវា ទោះដោយរបៀបណាក៏ដោយ ព្រះមានបន្ទូលដូច្នេះ។"

ប្រាំឆ្នាំកន្លងផុតទៅ។ "តើអូនមានអារម្មណ៍យ៉ាងណាឥឡូវ អូនសម្លាញ់?"

"មិនខុសគ្នាទេ។"

"យើងនឹងមានដោយរបៀបណាក៏ដោយព្រះទ្រង់មានបន្ទូលដូច្នោះ។"

130 តើវាជាអ្វី? គាត់មានការសន្យារបស់ព្រះ។ គាត់ជឿដល់ព្រះ ហើយគាត់បានប្រព្រឹត្តដូចព្រះជាម្ចាស់ គាត់កាន់ជាប់ នៅក្នុងព្រះបន្ទូលសន្យាដែរ។

131 ម្ភៃប្រាំឆ្នាំបានកន្លងផុតទៅ។ គ្រប់របស់ទាំងអស់ បានប្រែទៅជាលឿង ប៉ុន្តែនាងនៅតែកាន់ជាប់នឹងការនោះ។ ឥឡូវ គាត់ចាស់កោងខ្នងហើយ ហើយគាត់មានរូបរាងគួរឲ្យខ្លាច! ហើយស្បូនរបស់សារ៉ាដូចជាស្លាប់អ៊ីចឹងហើយគាត់ ក៏មិនអាចដែរ។ ហើយស្ថានភាពបែបណាដែលពួកគេកំពុងស្ថិតនៅ!

132 "តើអ្នកមានអារម្មណ៍យ៉ាងណា លោកអ័ប្រាហាំបិតានៃមនុស្សជាតិ?" មិត្តភក្តិរបស់គាត់ ដែលជាអ្នកធ្វើជាជឿព្រះដែរ នឹងនិយាយទៅកាន់គាត់។

133 "មែនហើយ! ថ្វាយសិរីល្អដល់ព្រះ ខ្ញុំមានអារម្មណ៍ល្អណាស់។ យើងនឹងមាន កូនទោះយ៉ាងណាក៏ដោយ" ព្រោះ គាត់មិនបានស្ទាក់ស្ទើរក្នុងការសន្យារបស់ទ្រង់ តាមរយៈការមិនជឿនោះទេ។ ប៉ុន្តែ ឈរមាំដោយការសរសើរតំកើងព្រះ

ជឿជាក់ ថាអ្វីដែលព្រះមានបន្ទូលទ្រង់អាចធ្វើបាន។ អាម៉ែន។ នេះគឺជាលក្ខណៈរបស់អ្នកជឿ។

134 ចុះអ្នកវិញ? ឃើញទេ? ចុះយើងវិញ តើជាកូនចៅរបស់អ័ប្រាហាំង? តើយើងទទួលស្គាល់ព្រះបន្ទូលព្រះដូចជាការសន្យាឬទេ ហើយចរិកលក្ខណៈរបស់យើងបានបង្ហាញថាយើងប្រាកដជាជឿហើយឬនៅ? ឬតើអ្នកគ្រាន់តែស្ទាក់ស្ទើរលោតពី*នេះ* ហើយទៅ*ទីនោះ* ហើយចុះទៅ*នេះ* ហើយនិយាយពីនេះ ពីនោះទៅវិញទៅមកអំពីវា? ហើយពួកយើងមិនមែនជា គ្រីស្ទានទេ យើងគ្រាន់តែធ្វើដូចអ្នកមានជំនឿប៉ុណ្ណោះ។

135 ប៉ុន្តែ ពេលដែលយើងឈរមាំក្នុងសេចក្តីសន្យានោះ និងនៅជាប់ជាមួយវា! លោកអ័ប្រាហាំបានធ្វើដូច្នោះ។

136 ឥឡូវនេះ យើងបានដឹងថា ថ្ងៃមួយគាត់ឃើញបុរសបីនាក់បានកំពុងដើរមក។ ព្រះគម្ពីរមានបន្ទូលនៅទីនេះថា "វាក្តៅនៅថ្ងៃនោះ" ប្រហែលពេលរសៀល។ បុរសទាំងនេះ បាននិយាយទៅកាន់គាត់។ យើងបានដឹងថា ពួកគេទាំងពីរនេះ បានធ្វើដំណើរទៅក្រុងសូដុម។ ខ្ញុំជឿថា យើងនឹងនិយាយនៅយប់មុន។ មានម្នាក់បានស្នាក់នៅជាមួយគាត់។

137 មើលម្នាក់នេះហើយ ដែលគាត់បានហៅ...ដែលបាននៅជាមួយគាត់ តើបុរសនោះបានធ្វើអ្វីខ្លះ។ លក្ខណៈមួយត្រូវបានកំណត់អត្តសញ្ញាណ ដោយលក្ខណៈរបស់ទ្រង់ថាទ្រង់ជាអេឡូហ៊ីម។

138 អេឡូហ៊ីម ជាព្រះបន្ទូលដំបូងនៅក្នុងព្រះគម្ពីរនេះ "កាលដើមដំបូងឡើយព្រះ..." ឥឡូវតើមានបងប្អូនអ្នកប្រាជ្ញណាដឹងថាពាក្យ *ព្រះ* នៅទីនោះមានន័យយ៉ាងម៉េចជាភាសាហេព្រើនេះគឺ "អេឡូហ៊ីម" ដែលមានន័យថា "ឫទ្ធានុភាពខ្លាំងក្លាបំផុត គង់នៅខ្លួនឯងលើទាំងអស់" មិនត្រូវការជំនួយពីនរណាម្នាក់នោះទេ មិនត្រូវការ នរណាម្នាក់បកស្រាយនោះទេ ទ្រង់ធ្វើដោយខ្លួនឯង។ ទ្រង់ជាព្រះដែលគ្រប់គ្រាន់ គង់នៅគ្រប់ទីកន្លែង សព្វញ្ញូញាណ មានគ្រប់អំណាចចេស្តា។ ទ្រង់គឺជាព្រះ។

139 ទ្រង់នៅទីនោះ។ ឥឡូវនេះគឺលោកអ័ប្រាហាំ ជា បុព្វបុរសដែលកាន់តាមព្រះបន្ទូលមួយនេះ មើលទៅមិត្តម្នាក់នេះ។ ហើយនៅពេលដែលមិត្តម្នាក់នេះងាកមើលទៅឯតង់ គាត់(ទ្រង់)និយាយថា "តើប្រពន្ធរបស់ឯងនៅឯណា?"

និយាយ "នាងនៅក្នុងតង់ ខាងក្រោយអ្នក"។

140 និយាយថា "ខ្ញុំនឹងទៅសួរសុខទុក្ខអ្នកតាមពេលវេលានៃជីវិត ហើយអ្នកនឹងមានកូនដែលអញបានសន្យា។"

141 ហើយសារ៉ានាងបានសើចអំពីការនេះ។ ហើយម្នាក់កំពុងនិយាយទៅគាត់សួរថាសារ៉ានិយាយអ្វីនៅក្នុងតង់ពីក្រោយគាត់(ទ្រង់)នេះ។

142 ឥឡូវនៅក្នុងលោកុប្បត្តិអ្នកនឹងអាននៅទីនោះ។យើងឃើញថា អ័ប្រាហាំបន្ទាប់ ពីបុរសម្នាក់នេះបានបញ្ជាក់ពីខ្លួនឯង...

143 តើជាអ្វីទៅ? ហេព្រើរ ជំពូក៤ ខ១២ បានមានបន្ទូលថា "នេះជា ព្រះបន្ទូលរបស់ព្រះដែលមុតស្រួច ដែលមានអនុភាព ជាងដាវមុខពីរទៅទៀត អ្នកយល់ពីគំនិតនេះទេ។"

144 ទ្រង់បានដឹងថានេះជាបុរសម្នាក់។ ទ្រង់ដឹងថានៅស្រុកនោះ គ្មានព្យាការីទេ ប៉ុន្តែគាត់ ដូច្នេះ នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់បានគង់ក្នុងគាត់។ ហើយគាត់ជាព្យាការីម្នាក់ ហើយព្រះបន្ទូលនឹងមកដល់ព្យាការីនេះ។

145 ដូចគ្នានឹងរឿងរបស់លោកយ៉ូហានបាទីស្ទដែរ។ គ្មានព្យាការីទេ អស់ពេលបួនរយឆ្នាំមកហើយ ខ្ញុំចាំ...

146 ប្រហែលជាបណ្ឌិតដាវីស អង្គុយនៅទីនេះយប់នេះ ដែលជាបេសកជនចាស់គ្រូអធិប្បាយបាទីស្ទដែលបានជ្រមុជទឹក ឲ្យខ្ញុំក្នុងសេចក្តីជំនឿនោះ។ គាត់បានជជែកជាមួយខ្ញុំ។ គាត់បាននិយាយថា "លោក ប៊ីលលី អ្នកគ្រាន់តែជាកូនក្មេងទេឥឡូវនេះ ចូរស្តាប់ខ្ញុំ។"

ខ្ញុំបាននិយាយថា "ត្រូវហើយ បងប្រុសដាវីស ខ្ញុំកំពុងស្តាប់។"

147 គាត់បាននិយាយថា "អ្នកឃើញទេលោកយ៉ូហាន មិនបានទទួលបុណ្យជ្រមុជទឹកនោះទេ។ ដូច្នេះគាត់បានធ្វើពិធីបុណ្យជ្រមុជទឹក ប៉ុន្តែគាត់មិនទាន់បានជ្រមុជទឹកនៅឡើយ គ្មាននរណាម្នាក់សក្តិសម នឹងជ្រមុជទឹកឲ្យគាត់ឡើយ។" នោះជាទ្រឹស្តីដែលបាទីស្ទបានគិត។ "ហើយ ព្រះយេស៊ូវបានយាងមក ហើយមាន

បន្ទូលបន្ទាប់មក...លោកយ៉ូហានបាននិយាយថា 'ខ្ញុំមិនអាចធ្វើពិធីជ្រមុជទឹកដល់ទ្រង់ទេ ហេតុអ្វីបានជាព្រះអង្គ មានព្រះបន្ទូលមកខ្ញុំដូច្នេះ?' ហើយទ្រង់មានបន្ទូលថា 'សូមធ្វើដូច្នេះទៅ។'" ទ្រង់មានបន្ទូលថា "នៅពេលដែលគាត់ 'ជ្រមុជ'ទ្រង់ទៅ" មានបន្ទូលទៀតថា "អ្នកឃើញទេ បន្ទាប់មកព្រះយេស៊ូវ បានទទួលបុណ្យជ្រមុជទឹកពីលោកយ៉ូហាន។ ហើយ នៅពេលដែលទ្រង់បានងើបពីទឹកមក ផ្ទៃមេឃបើកចំហហើយទ្រង់ បានឃើញ ព្រះលេចមកជាទម្រង់សត្វព្រាបមួយហើរចុះមក ហើយទុំលើទ្រង់ មានបន្ទូលថា 'នេះជាកូនស្ងួនភ្ងាអញជាទីពេញចិត្តអញណាស់។'" ប៉ុន្តែលោកដាវីបានបដិសេដការនេះ គាត់យល់ខុស។

148 ឃើញទេ លោកយ៉ូហានគឺជាព្យាការីម្នាក់ ហើយព្រះបន្ទូលតែងតែ មកកាន់ព្យាការី។ ដូច្នេះ បើសិនជាព្រះបន្ទូលក្លាយជាសាច់ឈាមក៏ដោយ គឺត្រូវតែមកកាន់ព្យាការី ព្រោះគាត់ ជាអ្នកបញ្ជាក់ប្រាប់ពីព្រះបន្ទូលរបស់ព្រះ ហើយចរិកលក្ខណៈរបស់គាត់បានកំណត់ដូច្នោះ។ នៅទីនេះ ព្រះបន្ទូលមកដល់ហើយ ឥឡូវ តើមានអ្វីកើតឡើង? កាលណាដែលគាត់ដើរចូលទៅដល់មុខព្រះយេស៊ូវ លោកយ៉ូហានបាននិយាយថា "ខ្ញុំត្រូវតែធ្វើពិធីជ្រមុជទឹកដល់ទ្រង់ឬ? ហេតុអ្វីបានជា ទ្រង់មករកខ្ញុំវិញ។"

149 ព្រះយេស៊ូវមានបន្ទូលថា "សូមឱ្យការនេះបានសម្រេចដូច្នេះចុះ សំរាប់ជាគំរូដល់ពួកយើង (វាជាការចាំបាច់ណាស់សម្រាប់យើង) ដើម្បីបំពេញ សេចក្តីសុចរិតទាំងអស់។" លោកយ៉ូហានជាព្យាការី ទ្រង់គឺជាព្រះបន្ទូលនេះ។ ទ្រង់គឺជាយញ្ញបូជា ហើយទ្រង់ត្រូវតែសម្អាត ដើម្បី ចូលទៅក្នុងព័ន្ធកិច្ចនៅផែនដីនេះ។ ហើយលោកយ៉ូហានបានជ្រមុជទឹកអោយទ្រង់ ព្រោះគាត់បានដឹងថា។ "វានឹងកើតមានដូច្នេះ។ ការនោះ នឹងកើតមានដូច្នេះ សំរាប់ជាគំរូដល់ពួកយើង ដើម្បីបំពេញសេចក្តីសុចរិតទាំងអស់។" យញ្ញបូជា ត្រូវតែលាងឲ្យស្អាត ពេលដែលបានបង្ហាញ ដូច្នេះហើយលោកយ៉ូហាន បានធ្វើពិធីជ្រមុជដល់ទ្រង់។ ព្រះយេស៊ូវមិនបានធ្វើពិធីជ្រមុជទឹក ឲ្យលោក យ៉ូហានទេ។ លោកយ៉ូហានជាអ្នកធ្វើពិធីជ្រមុជឲ្យ ព្រះយេស៊ូវ។ "ការនេះ ត្រូវបានសម្រេចដូច្នេះ។"

150 សូមចំណាំថា នេះគឺលោកអ័ប្រាហាំ ហើយគាត់នៅមានព្រះបន្ទូល របស់ព្រះជាម្ចាស់។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បានគង់ក្នុងគាត់។ គាត់គឺជា ព្យាការី

ម្នាក់។ ហើយឥឡូវនេះព្រះបន្ទូលបានមកដល់។ ទ្រង់បានហៅគាត់ថា "អ័ប្រាហាំ" មិនមែន*អាប់រ៉ាម* ទេ។

151 ប៉ុន្មានថ្ងៃមុនពេលដែល ទ្រង់បានហៅឈ្មោះរបស់គាត់ថាលោក អាប់រ៉ាម—អាប់រ៉ាម ឥឡូវនេះជាអ័ប្រាហាំ។ ប្រពន្ធរបស់គាត់ ពីមុនឈ្មោះ សារាយ តែឥឡូវនេះនាងឈ្មោះ "សារ៉ា" មិនមែន S-a-r-r-a ឬ S-a-r-a-h ទេ។ ហើយមិនមែន (A-b-r-a-h-a-m) A-b-r-a-m ប៉ុន្តែ A-b-r-a-h-a-m អ័ប្រាហាំ។

152 ហើយបុរសម្នាក់នេះ បានទទួលស្គាល់ខ្លួនឯង នៅពេលដែលគាត់បាននិយាយថា "អ័ប្រាហាំ!" អូ ខ្ញុំអើយ!

លោកអ័ប្រាហាំទូលទ្រង់ថា "អេឡូហ៊ីម!"

153 មានព្រះបន្ទូលនិងព្យាការីនៅជាមួយគ្នា ទាំងពីរនេះបានស្គាល់គ្នា។

154 អេឡូហ៊ីមទ្រង់មានបន្ទូលថា "តើប្រពន្ធរបស់អ្នក សារ៉ានៅឯណា?"

155 គាត់បាននិយាយថា "នាងគឺជានៅក្នុងតង់ដែលនៅក្រោយអ្នក" ។ ហើយ... បន្ទាប់មកការអស្ចារ្យនេះត្រូវបានធ្វើឡើង។ អេឡូហ៊ីម! លោកអ័ប្រាហាំ បានហៅទ្រង់ "ព្រះដែលមានគ្រប់ការទាំងអស់ គ្រប់រិទ្ធានុភាព គ្រប់ទាំងអំណាចចេស្តា។"

156 ព្រះយេស៊ូវមានបន្ទូលថានៅពេលដែលទ្រង់គង់នៅលើផែនដី ទ្រង់បានធ្វើការដូចដែលអេឡូហ៊ីមបានធ្វើដែរ។ នោះជាការកំណត់លក្ខណៈជាព្រះ។

157 ហើយទ្រង់មានព្រះបន្ទូលមុនថា "នៅក្នុងថ្ងៃចុងក្រោយនេះ គឺជាការយាងមក របស់ព្រះបុត្រានៃព្រះ នៅពេលដែលទ្រង់បានបង្ហាញឱ្យដឹងថា ការកំណត់នេះនឹងប្រព្រឹត្តទៅសារជាថ្មីម្តងទៀត ដូចជានៅក្រុងសូដុមដែរ។" អេឡូហ៊ីមនឹងគង់កណ្តាលចំណោមរាស្ត្ររបស់ទ្រង់ ដោយឫទ្ធានុភាពខ្លាំងក្លាបំផុត! នោះហើយជាអ្វីដែលបទគម្ពីរបានចែង។ អេឡូហ៊ីមគង់កណ្តាល ចំណោមមនុស្សទាំងអស់!

158 អស់រយៈពេលសែសិបឆ្នាំ លោកបានធ្វើពិធីជ្រមុជទឹកដល់យើង ដោយព្រះវិញ្ញាណបរិសុទ្ធ អេឡូហ៊ីម ព្រះជាម្ចាស់! ហើយពួកជំនុំ...

159 មើល អ័ប្រាហាំបានមើលឃើញទីសម្គាល់មួយ គឺការត្រាស់ហៅមួយផ្សេងទៀត ទីសម្គាល់មួយការត្រាស់ហៅមួយ ការត្រាស់ហៅមួយទីសម្គាល់មួយ ដើម្បីរង់ចាំកូនដែលបានសន្យានោះ។ ប៉ុន្តែ ទីសម្គាល់ចុងក្រោយ ដែលគាត់ បានឃើញបានលេចមក ដែលជាការយាងមកលេងជាចុងក្រោយ នៃព្រះមុនពេល ដែលកូន

ដែលបានសន្យាមកដល់នោះ គឺអេឡូហ៊ីមទំរង់ជាសាច់ឈាមមនុស្ស។ បន្ទាប់មក កូនដែលបានសន្យាក៏មកដល់។

160 ហើយពូជរបស់អ័ប្រាហាំកំពុងរង់ចាំកូនដែលបានសន្យា គឺព្រះយេស៊ូវគ្រីស្ទ។ ហើយពួកគេបានឃើញទីសំគាល់មួយ ដែលជាការហូរមក នៃព្រះវិញ្ញាណបរិសុទ្ធ និយាយក្នុងភាសា និងការព្យាបាលនៃព្រះជាដើម។ ប៉ុន្តែពេលដែលកូនមនុស្ស បើកសម្តែង អេឡូហ៊ីមនឹង ត្រឡប់ទៅជាពូជនៃអ័ប្រាហាំវិញ និងបើកបង្ហាញរឿង ដដែល ដូចដែលទ្រង់នឹងបើក សម្តែងនៅថ្ងៃនោះ អាម៉ែន អេឡូហ៊ីមដូចពីមុន! តើហេតុអ្វី? នោះគឺជាលក្ខណៈពិសេសរបស់ព្រះ។

161 ឥឡូវនេះប្រសិនបើ ព្រះគ្រីស្ទជាព្រះ "លោកិយ៍នឹងមិនស្គាល់ខ្ញុំ តែអ្នករាល់គ្នា នៅតែឃើញខ្ញុំ ព្រោះខ្ញុំនឹងនៅជាមួយអ្នក សូម្បីតែក្នុងថ្ងៃចុង បញ្ចប់ នៃផែនដី ក៏ដោយ។ ការងារដែលខ្ញុំធ្វើ អ្នកនឹងធ្វើដូចគ្នាដែរ។"

162 ព្រះយេស៊ូវបានមានបន្ទូលនៅក្នុង—ក្នុងលូកាជំពូកទី ១៧ដូច្នេះ ។ ល្អណាស់ នៅពេលដែលយើងជឿពិតប្រាកដ អ្នកនិងយល់ នៅថ្ងៃចុងបញ្ចប់នៃផែនដីនេះថា ការកំណត់នេះ នឹងកើតមានឡើងជាថ្មីម្តងទៀត។

163 ដូច្នេះ នៅគម្ពីរហេព្រើរ ជំពូក១ ខ១ បានចែងថា "ព្រះ កាលពីដើមតាមរយៈ ពួកព្យាការីបានសម្តែងពីអង្គទ្រង់ ក្នុងថ្ងៃចុងក្រោយនេះ បានសម្តែងពីការរស់ពី សុគតឡើងវិញនៃព្រះរាជបុត្រារបស់ទ្រង់" ដោយការផ្តល់ឲ្យ ក្រុមជំនុំដូចគ្នា ដូចដែលទ្រង់បានធ្វើ ហេព្រើ ជំពូក១៣ ខ៨ដែរ ត្រឹមត្រូវណាស់។

164 គ្មានស្លាបណាមួយ អាចដកចេញពីការនោះបានទេ។ នោះគឺជាស្លាបឥន្ទ្រី។ ពួកគេនៅជាប់ ព្រោះពួកគេជាបក្សីស្ថានសួគ៌។ [កន្លែងទទេនៅលើកាសែត—Ed។]...ពួកគេចិញ្ចឹមវាដោយអាហារឥន្ទ្រី។

165 ឥឡូវនេះយើងកត់សម្គាល់ឃើញថា "កាលពីដើម ច្រើនដងច្រើនបែបទ្រង់ មានបន្ទូលទៅកាន់ពួកឰយុកោតាមរយៈព្យាការី នៅថ្ងៃចុងក្រោយនេះទ្រង់មាន បន្ទូលតាមរយៈបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ដោយលើកទ្រង់ពីការសុគតឡើងវិញ។" ហើយទ្រង់គង់នៅ កណ្តាលចំណោមយើង បន្ទាប់ពីពីរពាន់ឆ្នាំ ព្រះយេស៊ូវដដែលមិនមែនហោរាមួយក្នុងចំនោមនោះទេ ព្រះយេស៊ូវ ហាលេលូយ៉ា ព្រះរាជបុត្រា ដែលបានរស់ពីសុគតឡើងវិញរបស់ព្រះជាម្ចាស់!

166 ព្រះយេស៊ូវមានបន្ទូល ថ្ងៃមួយទ្រង់មានបន្ទូលថា "ពូជឃោឃៅ និងគួរឲ្យខ្ពើម ស្វែងរកទីសំគាល់ ហើយពួកគេ នឹងទទួលបានទីសម្គាល់។" គឺជាមនុស្សអាក្រក់ ហើយកំផិតនៅជំនាន់នេះ។ តើមានពេលណាដែលមនុស្សអាក្រក់ ហើយផិតក្បត់ ច្រើនជាង ឥឡូវនេះ?

167 "ដូចដែល នៅថ្ងៃរបស់លោកយ៉ូណាស ដូចដែលលោកយ៉ូណាស បាន នៅក្នុងពោះត្រីធំមួយអស់រយះពេលបីថ្ងៃបីយប់ ដូច្នេះព្រះរាជបុត្រានៃព្រះ ត្រូវតែគង់នៅក្នុងចិត្តនៃផែនដីបីថ្ងៃបីយប់ដែរ។"

168 បន្ទាប់មក "ជំនាន់មនុស្សអាក្រក់ហើយកំផិត" ត្រូវបាន ទទួលទីសម្គាល់។ តើជាទីសម្គាល់ប្រភេទអ្វី? ទីសម្គាល់នៃការរស់ឡើងវិញ។ ហើយយើងបានទទួល វានៅថ្ងៃនេះ បន្ទាប់ពីពីរពាន់ឆ្នាំមកហើយ ទ្រង់គឺនៅរស់។ ទ្រង់គឺនៅកណ្តាល ចំណោមយើង នៅយប់នេះ ដូចកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត ទ្រង់ បានបង្ហាញអង្គទ្រង់ដោយលក្ខណៈពិសេសរបស់ព្រះ បើកសម្តែងព្រះបន្ទូលនៅ ថ្ងៃនេះ ដែលទ្រង់បានសន្យាថានឹងធ្វើ។ អាម៉ែន។

169 មានព្រះបន្ទូល។ ឥឡូវនេះ តើអ្នកនឹងជឿលើទីសម្គាល់ទេ ជារឿងបន្ទាប់ នៅថ្ងៃចុងក្រោយ អត្តសញ្ញាណរបស់ទ្រង់ គឺព្រះរាជបុត្រារបស់ទ្រង់? សូម កត់ចំណាំ។

170 ព្រះជាម្ចាស់ មានព្រះបន្ទូលមកកាន់លោកម៉ូសេ តាំងពីដើម។ នៅក្នុង ចោទិយកថា ជំពូក ១៨ ខ១៥ បានមានបន្ទូលថា "ព្រះយេហូវ៉ាជាព្រះនៃឯងទ្រង់ នឹងបណ្តាលឲ្យមានហោរា១កើតឡើងពីពួកបងប្អូនឯងឲ្យដូចជាអញ។" ឥឡូវចូរ មើល។ នោះហើយជាព្រះបន្ទូល។ នោះគឺជាព្រះបន្ទូល។ នោះគឺជាព្រះ។ នោះ មិនមែនជា លោកម៉ូសេទេ។ តើលោកម៉ូសេដឹងដោយរបៀបណា ថាគាត់គឺជា មនុស្សម្នាក់? ប៉ុន្តែព្រះជាម្ចាស់ បានមានបន្ទូលតាមរយៈលោកម៉ូសេ។ អ្នកជឿ ដូច្នោះទេ? មែនហើយ។

171 ឥឡូវ ចូរកត់សម្គាល់ព្រះយេស៊ូវ មើលតើយ៉ាងណា—លក្ខណៈរបស់ទ្រង់ ទទួលស្គាល់ថាជាព្រះបន្ទូលសន្យាដ៏ពិត។ ទ្រង់ពិតជា សម្រេចវាបាន។ ទ្រង់បាន ស្គាល់ដោយលក្ខណៈពិសេសដែលម៉ូសេបាននិយាយថាទ្រង់នឹងបែបនេះ។

172 ពួកគេជាច្រើនដូចសព្វថ្ងៃនេះចង់ឃើញអ្នកដឹកនាំអស្ចារ្យ។ "អូ! នេះគឺជា បណ្ឌិត។ *ដូចនេះ—និង—ដូចនេះ*។ គាត់បានរៀនចប់ពីសាកលវិទ្យាល័យហា

ហ្វដ (Hartford)។ ឬគាត់ចេញពីកន្លែងណាមួយ ដែលធំមួយចំនួនដូចនេះដែរ។" នោះមិនមែន ជាការកំណត់អត្តសញ្ញាណរបស់ព្រះទេ។ ទេ ទេ។ នោះមិនមែនទេ។ ព្រះបន្ទូលគឺជាអ្វីដែលព្រះបានកំណត់។ ឃើញទេ?

173 ព្រះយេស៊ូវ មិនមែនជាអ្នកប្រាជ្ញទេ ហើយក៏មិនមែនជាបូជាចារ្យម្នាក់ឡើយ ហើយក៏មិមែនជាបុព្វបុរសម្នាក់ នៃផែនដីឡើយ។ ទ្រង់ គឺជាអ្នកលះបង់ ដើម្បីជួយសង្គ្រោះលោកិយ។

174 ប៉ុន្តែ ព្រះបានសម្រេចព្រះបន្ទូលរបស់ទ្រង់តាមរយៈទ្រង់ផ្ទាល់ដែលធ្វើឲ្យទ្រង់ជាអេម៉ាញូអែល។ នោះជាការកំណត់អត្តសញ្ញាណរបស់ទ្រង់។ ឥឡូវនេះ នៅទីនេះ ព្រះយេស៊ូវបានជួបការពិតនូវអ្វី ដែលព្រះបានធ្វើកាលពីដើមថា ទ្រង់នឹងសម្រេចការនេះតាមរយៈលោកម៉ូសេ នេះហើយជាអ្វីដែលទ្រង់នឹងធ្វើ។

175 ឥឡូវនេះ សូមមើល នៅពេលដែលទ្រង់បានជួបជាមួយ លោកពេត្រុស ដូចដែលយើងបានសម្តែងរឿងនៅយប់មុនដែរ នៅពេលដែល ទ្រង់បានជួប លោកពេត្រុស ហើយបានប្រាប់ពេត្រុសពីន័យនៃឈ្មោះរបស់ គាត់។ ទីសម្គាល់ នេះបានបញ្ជាក់ពីឈ្មោះរបស់ព្រះមេស្ស៊ី ទៅលោកពេត្រុស ដ្បិតព្រះបន្ទូលចែងថា "ព្រះអម្ចាស់ជាព្រះរបស់អ្នក នឹងលើក ព្យាការីឡើង។"

176 ហើយលោកពេត្រុស ដែលជាស៊ីម៉ូនបានកើតជាថ្មី លោកស៊ីម៉ូនបានរស់ឡើងវិញ ដែលជាកន្លែងដែលគាត់ធ្លាប់នៅ។ ហើយព្រះយេស៊ូវបានមើលទៅគាត់មានព្រះបន្ទូលថា "អ្នកឈ្មោះស៊ីម៉ូន ហើយអ្នកជាកូន របស់លោក យ៉ូណាស។" ដែលបានបង្ហាញពីលក្ខណៈរបស់ព្រះគ្រីស្ទ គឺជាព្រះបន្ទូលនោះដែលម៉ូសេបានសន្យា។ ពេត្រុសបាន ទទួលស្គាល់ថា នេះជាទីសម្គាល់ដែលបានបញ្ជាក់ថាព្រះយេស៊ូវជាព្រះមេស្ស៊ី។ "ព្រះជាម្ចាស់គង់ក្នុងព្រះគ្រីស្ទ" ដែលបានចាក់ប្រេងតាំងសម្រាប់ថ្ងៃចុងក្រោយ។ ទៅកាន់ ណាថាណែល...ចាំថាទ្រង់បានប្រាប់ស៊ីម៉ូនពីឈ្មោះ របស់គាត់។

177 ឥឡូវ សូមមើលទៅ ណាថាណែលទ្រង់បានប្រាប់ពីអ្វីដែលគាត់បានធ្វើ។ "អ្នក គឺនៅក្រោមដើមឈើ នៅពេលដែលខ្ញុំបានឃើញអ្នក។" ដែលបញ្ជាក់ថាទ្រង់ជាព្រះមេស្ស៊ី។

178 ទ្រង់មានបន្ទូលថា "ទ្រង់ជាព្រះបុត្រារបស់ព្រះ។ ទ្រង់គឺជាស្តេចនៃសាសន៍អ៊ីស្រាអែល។" ទ្រង់ត្រូវបានកំណត់អត្តសញ្ញាណ ដោយលក្ខណៈពិសេសនៃ

ព្រះបន្ទូលសន្យាថា ទ្រង់ត្រូវតែជាព្រះមេស្ស៊ី។ "ព្រះអម្ចាស់ជាព្រះនៃឯងនឹងលើកព្យាការីឡើង។"

179 ស្រ្តីម្នាក់ នៅក្បែរអណ្តូងទឹក ទ្រង់បានប្រាប់នាងថានាងជាអ្វី ហើយនោះបានបញ្ជាក់ថាទ្រង់ ពិតជាព្រះមេស៊ីដែលបានសន្យា? ឃើញទេ?

180 លក្ខណៈរបស់ទ្រង់លក្ខណៈពិសេសនោះគឺជាព្រះបន្ទូលដែលបាន កំណត់។ គឺលក្ខណៈពិសេសរបស់ទ្រង់បានបង្ហាញថាព្រះបន្ទូល គឺជាព្រះដូច្នេះគឺព្រះបានកំណត់អត្តសញ្ញាណក្នុងព្រះគ្រីស្ទ។ ឥឡូវនេះ សូមមើល។ ហើយកត់ទុក។

181 ទៅកាន់ពេត្រុសទ្រង់បានបញ្ជាក់ទៅកាន់ពេត្រុស ដោយការហៅ ឈ្មោះរបស់គាត់។ ទ្រង់បានបញ្ជាក់ទៅកាន់ណាថាណែលដោយ ប្រាប់គាត់ពីអ្វីដែលគាត់បានធ្វើ។ ទ្រង់បានបញ្ជាក់ទៅកាន់ស្រ្តីម្នាក់ ដោយប្រាប់នាងថានាងជាអ្វី។ អ្វីជាគាត់...*គាត់* ជានរណា! អ្វីដែល *គាត់* បានធ្វើ ហើយ *នាង* ជាអ្វី។ ទ្រង់បានបញ្ជាក់លក្ខណៈពិសេសនៃព្រះមេស្ស៊ីរបស់ទ្រង់ ដែលជាព្រះមេស្ស៊ី។

182 មើល ទៅស្ត្រីម្នាក់នេះ បាននិយាយពី អ្វីដែលដូចគ្នា។ "លោក ខ្ញុំដឹងថាអ្នកគឺជាព្យាការីម្នាក់។ យើងមិនមានព្យាការី អស់រយៈពេលរាប់រយឆ្នាំ មកហើយ។ យើងមានក្រុមជំនុំជាច្រើន មានជំលោះជាច្រើននិងនិកាយខុសៗគ្នា ប៉ុន្តែ យើងមិនមានព្យាការី អស់រយៈពេលរាប់រយឆ្នាំមកហើយ។ យើង ដឹងថាពេលព្រះ មេស្ស៊ី យាងមក នេះគឺជាអ្វីដែលបានបញ្ជាក់ អត្តសញ្ញាណទ្រង់។"

183 ទ្រង់មានបន្ទូលថា "ខ្ញុំជា ទ្រង់ដែលមានបន្ទូលទៅកាន់អ្នក។" គ្មានអ្វីដែលមិនច្បាស់អំពីការនោះទេ "ខ្ញុំគឺជាទ្រង់។" នោះហើយ បានបញ្ជាក់ពីទ្រង់។

184 ស្រ្តីម្នាក់មានបញ្ហាធ្លាក់ឈាម នោះជាការបញ្ជាក់ថា ទ្រង់ជាព្រះបន្ទូល។ ដោយរបៀបណា? ដោយជំនឿរបស់នាងបានប៉ះទ្រង់។ ទ្រង់បានងាកមក ហើយមានព្រះបន្ទូលថា "នរណាប៉ះខ្ញុំ?" ទ្រង់ដឹងថាមានអ្វី មួយកើតឡើង។ ការនេះបានបង្ហាញថាព្រះយេស៊ូវជាព្រះមេស្ស៊ី។

185 នាងបានជឿវា ហើយនាងបាននិយាយថា "ប្រសិនបើខ្ញុំអាចពាល់ ព្រះពស្ត្រទ្រង់ ខ្ញុំនឹងបានជាសះស្បើយ។"

186 ដូច្នេះ កាលណា នាងបានប៉ះទ្រង់ ទ្រង់បែរទៅមានបន្ទូលថា "ឥឡូវនេះ អ្នក ណាបានពាល់ខ្ញុំ?" ហើយពួកគេទាំងអស់គ្នា បានបដិសេធការនោះ។ ប៉ុន្តែគឺ លក្ខណៈព្រះមេស្ស៊ីរបស់ទ្រង់...

187 អាម៉ែន! ខ្ញុំសង្ឃឹមថាអ្នកនឹងឃើញនោះ ក្រុមជំនុំអើយ។ សូមស្តាប់ដូចដែល យើងបានបញ្ជាប់។

188 នៅទីនោះនាងបានប៉ះទ្រង់។ នៅទីនោះមានមនុស្សរាប់រយនាក់ ប្រហែលជា ពួកគេព្យាយាមដើម្បីប៉ះទ្រង់។ ពេត្រុសបានស្តីបន្ទោសទ្រង់ ហើយបាននិយាយ ថា "ពួកគេទាំងអស់ គឺបានប៉ះទ្រង់។"

189 ទ្រង់មានបន្ទូលថា "មែនហើយ ប៉ុន្តែមាននរណាម្នាក់បានពាល់ខ្ញុំខុសពីគេ។" នោះជាការដែលខុសគ្នា នោះជាការប៉ះដោយជំនឿ អ្នកយល់ទេ? ទ្រង់មានបន្ទូល ទៀតថា "មានម្នាក់ពិតជាបានពាល់ខ្ញុំ។ នោះ គឺជាការប៉ះខុសពីគេ។ ខ្ញុំខ្សោយ។ កម្លាំងរបស់ខ្ញុំ បានចេញពីខ្ញុំ។ ដោយសារកម្លាំងរបស់ខ្ញុំបានចេញពីខ្ញុំ។" ឥឡូវនេះ ទ្រង់ឈរនៅទីនោះ។

190 ឥឡូវនេះ សូម្បីតែពួកសិស្សរបស់ទ្រង់បាននិយាយ នៅក្នុងពាក្យផ្សេងថា "ទ្រង់ស្តាប់ទៅដូចជាមានមនុស្សម្នាក់បានប្រព្រឹត្តខុសលើទ្រង់។ ហេតុអ្វី មនុស្ស គ្រប់គ្នាកំពុងប៉ះអ្នក។"

191 មើលទ្រង់ មើលការបញ្ជាក់របស់ទ្រង់ ឥឡូវនេះ។ ទ្រង់បានងាកមើលទៅហ្វូង មនុស្ស។ ទ្រង់បានចង្អុលហៅនាង នៅខាងស្តាំ អោយចេញមក។ នាងមិន អាច លាក់ខ្លួន បានទៀតឡើយ។ ទ្រង់បានប្រាប់នាង អំពីស្ថានភាព របស់នាង ហើយ បាននិយាយថា "ជំនឿរបស់នាង បានធ្វើឱ្យនាង ជាសះស្បើយហើយ។" នាង បានដឹងនៅពេលនោះ។

192 នាងបានដឹង នៅហេព្រើ ជំពូក៤ ខ១២ "ព្រះបន្ទូល គឺពិចារណាអស់ទាំង គំនិត ដែលចិត្តគិត ហើយដែលសំរេចដែរ។" លក្ខណៈរបស់ទ្រង់បានកំណត់ អត្តសញ្ញាណទ្រង់ជា "ព្រះបន្ទូលបង្កើតជាសាច់ឈាមហើយគង់ក្នុងចំណោម យើង។" អាម៉ែន។

193 ខ្ញុំគិតដូចគ្នាដែរ នៅរាត្រីនេះ បញ្ជាក់អត្តសញ្ញាណទ្រង់ ការរស់ឡើងវិញរបស់ ព្រះយេស៊ូវគ្រីស្ទ គង់នៅកណ្តាលចំណោមយើង ដូចកាលពីម្សិលមិញ ថ្ងៃនេះ និង

ជារៀងរហូត។ ឥឡូវនេះ ដូចជាហេព្រើរ ជំពូក១៣ ៥៨ នេះគឺជាការពិត ចរិក លក្ខណៈរបស់ទ្រង់ នឹងបញ្ជាក់អត្តសញ្ញាណទ្រង់ នៅថ្ងៃនេះ ដូចដែលទ្រង់បានធ្វើ ដូច្នោះដែរ។

194 សូមមើលនៅក្លេវប៉ាស និងពួកគេ បន្ទាប់ពីការរស់ឡើងវិញ។ ព្រះយេស៊ូវ បានបញ្ជាក់អង្គទ្រង់ផ្ទាល់ដោយវិធីដែលទ្រង់បានកាច់នំបុ័ងដែលទ្រង់បានធ្វើមុន ពេលដែលទ្រង់ត្រូវគេឆ្កាង។ ហើយពួកគេ...ដែលបានបញ្ជាក់អត្តសញ្ញាណនៃព្រះ "ដោយសារ វិធីដែលទ្រង់បានធ្វើ។"

195 ឥឡូវនេះ ប្រសិនបើ ទ្រង់មានវត្តមាននៅទីនេះ នៅយប់នេះ តើទ្រង់នឹង បញ្ជាក់អត្តសញ្ញាណអង្គទ្រង់យ៉ាងណា? ដូចដែល ទ្រង់បានធ្វើកាលពីម្សិលមិញ ដូចគ្នានៅថ្ងៃនេះ ហើយជារៀងរហូតដែរ។ វាជាការបញ្ជាក់អត្តសញ្ញាណនោះ។ ហេព្រើរជំពូក៤ បួន—...១៤ និង ១៥ ថា "ទ្រង់ឥឡូវនេះគឺ..." ទ្រង់មានបន្ទូលថា "ទ្រង់ គឺជាសង្ឃជាន់ខ្ពស់របស់យើង ដែលបានប៉ះដោយអារម្មណ៍នៃភាពមើលមិន ឃើញរបស់យើងនេះ។" ទ្រង់ជាសម្ដេចសង្ឃរបស់យើង ឥឡូវនេះ។ បន្ទាប់ពីការ រស់ឡើងវិញរបស់ទ្រង់ បន្ទាប់ពីការសុគតរបស់ទ្រង់ បន្ទាប់ពីការបញ្ចុះសពរបស់ ទ្រង់ បន្ទាប់ពីការរស់ឡើងវិញរបស់ទ្រង់ បន្ទាប់ពីការហោះឡើងរបស់ទ្រង់ អាម៉ែន ទ្រង់នៅតែដូច កាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត ទ្រង់ជាសង្ឃជាន់ខ្ពស់ ដែលបានប៉ះ ដោយអារម្មណ៍នៃសេចក្ដីជំនឿរបស់យើង។ អាម៉ែន។ ទ្រង់គឺដូច្នេះ ឥឡូវនេះ គ្រប់បុរសនិងស្ត្រី នៅទីនេះនឹងជឿទ្រង់។ ទ្រង់ គឺជាសង្ឃជាន់ខ្ពស់របស់ យើង ដូចកាលពីម្សិលមិញ នឹងថ្ងៃនេះ និងជារៀងរហូត។

196 ទ្រង់មានព្រះជន្មរស់ឡើងវិញ។ តើអ្នកជឿដែរឬទេ? [ក្រុមជំនុំ និយាយថា "អាម៉ែន។"—។Ed] លក្ខណៈរបស់ទ្រង់ បានបន្តបញ្ជាក់អត្តសញ្ញាណ របស់ទ្រង់ ដូចគ្នា នឹងពេលដែលទ្រង់ បានរស់នៅលើផែនដីនេះ។ ទ្រង់នៅតែមាន ព្រះជន្ម គង់នៅនៅទីនេះនៅយប់នេះដោយទំរង់ព្រះវិញ្ញាណបរិសុទ្ធ។ ទ្រង់ធ្លាប់ រស់នៅលើ ផែនដីនេះ។ ហើយលក្ខណៈរបស់ទ្រង់បាននៅជាមួយទ្រង់ ដូចដែល ទ្រង់តែងតែ ធ្វើ ប្រសិនបើទ្រង់នៅតែរស់នៅ។

197 ខ្ញុំសូមអរព្រះគុណ នៅយប់នេះ "ព្រះកាលពីដើម ច្រើនដងច្រើនបែប បាន មានព្រះបន្ទូលទៅពួកឰយុកោ តាមរយៈពួកព្យាការី នៅថ្ងៃចុងក្រោយនេះតាមរយៈ ព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ។"

198 ខ្ញុំអើយ ខ្ញុំមិនដឹងថា ខ្ញុំបាននិយាយអស់រយៈពេលយូរយ៉ាងនេះទេ។ ខ្ញុំបានភ្លេចថាវាផែងដូច្នេះ។ ខ្ញុំសំទោស។ ខ្ញុំគ្រាន់តែ...ខ្ញុំនឹងឈប់។

សូមឱ្យយើងបានអធិស្ឋាន។

199 ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ព្រះជាម្ចាស់ដែលមានព្រះទ័យមេត្តាករុណាដ៏អស្ចារ្យ! ព្រះអម្ចាស់អើយ ខ្ញុំ—ខ្ញុំ...ប្រហែលជាខ្ញុំនិយាយច្រើនបន្តិច។ ទូលបង្គំអធិស្ឋាន ព្រះជាម្ចាស់ ប្រសិនបើជាយូរពេក សូមទ្រង់បាន អត់ទោសអោយទូលបង្គំផង។ ប៉ុន្តែ ព្រះអម្ចាស់ ទូលបង្គំមិនអាចសុំការ អភ័យទោស ចំពោះអ្វីដែលទូលបង្គំបាននិយាយឡើយ។ ទូលបង្គំគ្រាន់តែ បាននិយាយ ពីអ្វីដែលទ្រង់បាន មានបន្ទូលនៅក្នុងព្រះបន្ទូលរបស់ទ្រង់នៅទីនេះប៉ុណ្ណោះ។

200 ឥឡូវនេះ គ្រាន់តែជាពាក្យមួយម៉ាត់ ឬពីរម៉ាត់ ពីទ្រង់ ប្រហែលជា អ្នករាល់គ្នានៅទីនេះនឹងស្គាល់ ពីព្រះបន្ទូលនេះនៅយប់នេះ។ មនុស្សដែលឈឺ នឹងបានព្យាបាល ពួកគេបានឃើញថា ទ្រង់នៅតែជាសម្តេចសង្ឃដ៏ឧត្តុង្គឧត្តម។ ទូលបង្គំបានអធិស្ឋាន ព្រះអម្ចាស់ នៅក្នុងប៉ុន្មាននាទីទៀតនេះ ទ្រង់នឹងធ្វើឱ្យសារនេះកើតមានឡើងសារជាថ្មីម្តងទៀតជាការពិត។ អ្វីដែលទូលបង្គំបាននិយាយ ដោយព្រះបន្ទូល សូមឲ្យលក្ខណៈរបស់ទ្រង់ បញ្ជាក់អត្តសញ្ញាណរបស់ទ្រង់ នៅកណ្តាលចំណោមយើង នៅយប់នេះ ទ្រង់ដូចគ្នា កាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត យើងអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូវ។ អាម៉ែន។

201 សុំមួយភ្លែតឥឡូវនេះ។ យើងខ្ញុំ—ខ្ញុំគ្រាន់តែមានការយឺតបន្តិច ប៉ុន្តែអ្នកទាំង អស់គ្នាអត់ធ្មត់បន្តិចទៀតក្នុងការអធិស្ឋានទេ ប្រហែលដប់ប្រាំ ឬម្ភៃនាទី? ប្រសិនបើបានសូមចាប់ដៃរបស់អ្នកឡើង ហើយនិយាយថា "យើង..." ត្រូវហើយ សូមអរគុណ—សូមអរគុណ។ ខ្ញុំសន្យាថានឹងអនុញ្ញាត ឱ្យអ្នកចេញនៅម៉ោងប្រាំបួនសាមសិប។ វាដល់ពេលហើយ ឥឡូវនេះ! វាមានពេលម្ភៃនាទី។ ដូច្នេះប្រសិនបើអ្នកគ្រាន់តែអនុញ្ញាតិឱ្យខ្ញុំប្រហែលដប់នាទី ខ្ញុំនឹងប្រញាប់។

202 សូមមើល តើសន្លឹកនៃការអធិស្ឋានអ្វីសម្រាប់ផ្តល់ឲ្យពួកគេនៅថ្ងៃនេះ ប្អូនប្រុសម្នាក់បាននិយាយថា "អូ។"—។Ed]? អូ? អ្វីកន្លែងណាដែលយើងនឹងត្រូវចាប់ផ្តើម នៅយប់មុន មួយ មួយ? ["ខ្ញុំគិតថាវាជាការមួយ។"] មែនហើយ អើ—ហើ។

203 ហើយបន្ទាប់មកយើង កាលពីយប់មុន យើងគ្រាន់តែ...ព្រះវិញ្ញាណ បរិសុទ្ធ... ខ្ញុំបានស្តាប់នៅថ្ងៃនេះហើយបាននិយាយម្តងទៀត នូវអ្វីដែលទ្រង់ មានបន្ទូល។ ឈ្មោះខ្លះជាភាសារបារាំង ខ្ញុំជា...ព្រះវិញ្ញាណបរិសុទ្ធ មានវិធីតែមួយ ដែលខ្ញុំអាចធ្វើវាបាន សូមរង់ចាំមើល។

204 អ្នកឃើញទេ ពេលខ្លះ នៅពេលដែលអ្នកឃើញនិមិ្មតមួយ អ្នកត្រូវតែត្រលប់ទៅមើលការបកប្រែ។ វាជាការបកស្រាយ។ និមិ្មតមួយ ដូចជា អ្នកបាន—បានឃើញ—ចៀមមួយប្រហែលមានន័យជាពោមចៀម។ ឃើញទេ អ្នកត្រូវតែមានការបកប្រែពីវា ហើយត្រលប់និមិ្មតនោះនិងបកប្រែវា។

205 ខ្ញុំបានកត់សម្គាល់ឃើញថា កាលពីយប់មិញ ខ្ញុំ—ខ្ញុំមិនអាចប្រកាសឈ្មោះបារាំងទាំងនោះបានទេ ខ្ញុំត្រូវតែប្រកបវាមួយៗ។

206 នៅអាហ្វ្រិក និងនៅជុំវិញទីនោះ ហូតថិនថូត និងអ្នកជឿសាសនា និងអ្វីផ្សេងទៀត វាគួរតែមានការប្រកបឈ្មោះរបស់ពួកគេ ហើយប្រាប់ពួកគេ ពីឈ្មោះរបស់ពួកគេ ដែលត្រូវប្រកបជាភាសារបស់ពួកគេ។ នោះពួកគេនឹងដឹង ពីឈ្មោះរបស់ពួកគេ នៅពេលដែលអ្នកបានប្រកបវាចេញមក។ ប៉ុន្តែ សូមមើល ទ្រង់បានស្គាល់គ្រប់ភាសាទាំងអស់។ ទ្រង់គឺជាព្រះ ដ៏អស់កល្បជានិច្ច។

207 ចូរចាប់ផ្តើមនៅរាត្រីនេះ អនុញ្ញាតឱ្យខ្ញុំបានហៅ ពីសន្លឹកចិតសិបប្រាំ ដល់សន្លឹកទីមួយរយនៅក្នុង អូ។ គឺអូ ជាអ្វីដែលទ្រង់បានមានព្រះបន្ទូល? ខ្ញុំ... ប្អូនប្រុសម្នាក់បាននិយាយថា "បាទ។ អូ" អូ អូ បាទ។ ត្រឹមត្រូវ។ តើអ្នកណាដែលបានសន្លឹកនៃការអធិស្ឋាន លេខចិតសិបប្រាំ សូមមើល? នៅក្នុង អូ សន្លឹកនៃការអធិស្ឋាន អូ ចិតសិបប្រាំ សូមលើកដៃរបស់អ្នកឡើង បើសិនជាអ្នកមានវា។ អូ របស់គាត់។ ត្រូវហើយ។ សូមអញ្ជើញមក*ទីនេះ* ។ ចិតសិបប្រាំ ប៉ែតសិប ប៉ែតសិបប្រាំ កៅសិប កៅសិបប្រាំ មួយរយ មកតាម*នេះ* ប្រសិនបើអ្នកមាន។ ត្រូវហើយ សូមឈរតម្រង់ជួរបន្ទាត់នៅទីនេះ សូមប្រញាប់ បន្តិច ព្រោះយើងគ្មានពេលច្រើនទេ។ ខ្ញុំគ្រាន់តែជឿថា អ្នកនឹងធ្វើវាបាន។

208 សូមមើល នៅក្នុងសន្លឹកនៃការអធិស្ឋានរបស់អ្នក។ នៅក្នុងសន្លឹក នៃការអធិស្ឋានរបស់អ្នកជិតខាងរបស់អ្នកដែរ។ តើជាអ្វីមួយ...ហើយប្រសិនបើ មាននរណាម្នាក់ នៅកន្លែងចង្អៀត សូមជួយបើកផ្លូវអោយពួកគាត់បន្តិច ដើម្បី អោយ

ពួកគាត់មកឈរតម្រង់ជួរ។ ដូច្នេះប្រសិនបើ ពួកគេមានអូ(0)លេខដូចជា អូចិតសិប—...

209 ចិតសិបប្រាំ ដល់មួយរយ សូមតម្រង់ជួរនៅ *ទីនេះ* ប្រសិនបើអ្នកមាន។ ទីកន្លែងណាក៏ដោយដែលអ្នកនៅ នៅយ៉ររនេះ នៅគ្រប់ទីកន្លែងជាច្រើនទៀត ហើយមកខាងនេះ ដើម្បីតម្រង់ជួរ អោយបានលឿនតាមដែលអាចធ្វើបាន ប្រសិនបើអ្នកមាន ធ្វើដូច្នេះដើម្បីសន្សំពេលវេលា។

210 ឥឡូវនេះ នៅអ្នកខ្លះ នៅទីនេះ ដែលអត់មានសន្លឹកនៃការអធិស្ឋាន សូមអ្នកបានលើកដៃឡើងហើយនិយាយថា "ខ្ញុំអត់មានសន្លឹកកាតអធិស្ឋានទេ បងប្រុសប្រានហាំប៉ុន្តែខ្ញុំជឿដូច្នេះ"? សូមលើកដៃរបស់អ្នកឡើង។

211 ឥឡូវ ចូរចងចាំថា ខ្ញុំនឹងនិយាយជាមួយអ្នក អំពីសម្ដេចសង្ឃ។ "ទ្រង់គឺជាសង្ឃជាន់ខ្ពស់ ដែលអាច ប៉ះបានដោយអារម្មណ៍ នៃការមិនឃើញ របស់យើងនេះ។" ទ្រង់គឺជា *ព្រះយេហូវ៉ា—យីរ៉េ* "ព្រះអម្ចាស់ជាអ្នកផ្ដល់យញ្ញបូជា។" ទ្រង់គឺព្រះ*យេហូវ៉ា—រ៉ាផា* "ព្រះអម្ចាស់ជាអ្នកដែលប្រោសជំងឺរបស់អ្នករាល់គ្នា។" តើអ្នកជឿទេ?[ក្រុមជំនុំនិយាយថា"អាម៉ែន។"—Ed។] ទ្រង់គឺជាព្រះយេហូវ៉ា-ម៉ាណាសេ។ ជា*ប្រដាប់រុំកំភួនដៃ* ជា*ខែល*មួយ ជាសន្តិភាព របស់យើង ទ្រង់នៅតែគង់នៅ។ ប្រសើរណាស់ តើប៉ុន្មាននាក់ដែល ជឿថា ទាំងអស់នោះ ជាឈ្មោះប្រោសលោះរបស់ព្រះយេហូវ៉ាដែលបានក្លាយជាព្រះយេស៊ូវ? ["អាម៉ែន។"—Ed។] ប្រាកដណាស់ទ្រង់ត្រូវតែក្លាយ។ បើទ្រង់—បើទ្រង់...ហេតុអ្វីបានជាពួកគេ មិនអាចញែកដាច់ពីគ្នា ដូច្នេះទ្រង់ត្រូវតែក្លាយជាអង្គទាំងនោះ។ ហើយប្រសិនបើទ្រង់នៅតែជាព្រះយេហូវ៉ា—យីរ៉េ ទ្រង់ជាព្រះយេហូវ៉ា—រ៉ាផា។ បើសិនទ្រង់ជាព្រះយេហូវ៉ា—យីរ៉េ...ទ្រង់គឺជាព្រះ*យេហូវ៉ា—យីរ៉េ* "ព្រះជាម្ចាស់ជាអ្នកផ្ដល់យញ្ញបូជា សម្រាប់សេចក្ដីសង្គ្រោះ" បន្ទាប់មកទ្រង់ជាព្រះ*យេហូវ៉ា—រ៉ាផា* បន្ទាប់មកទ្រង់ជា "ព្យាបាល ជំងឺរបស់យើង។" អាម៉ែន។ ការព្យាបាលអាចធ្វើទៅបាន ដោយព្រះជាម្ចាស់។

212 ប្រសើរណាស់ ខណៈពេលដែលយើងទាំងអស់គ្នាតម្រង់ជួរ ខ្ញុំមិនមានពេលមើថាពួកគេជានរណាហើយជាអ្វីនោះទេ។ ប៉ុន្តែឥឡូវអ្នកដែលដឹងថា មិនទាន់ស្គាល់ខ្ញុំសូមលើកដៃឡើង ហើយនិយាយថា "ខ្ញុំត្រូវការព្រះជាម្ចាស់។ ប៉ុន្តែអ្នក

មិនទាន់ស្គាល់ខ្ញុំទេ បងប្រុស ប្រានហាំ ប៉ុន្តែ ខ្ញុំត្រូវការព្រះជាម្ចាស់។ ខ្ញុំគ្រាន់តែលើកដៃរបស់ខ្ញុំឡើង។"

213 ឥឡូវនេះប្រសិនបើអ្នកគ្រាន់តែគិតតែប៉ុន្មាននាទី ចូរមើលដោយប្រុងប្រយ័ត្ន ហើយស្ងៀមស្ងាត់។ ឥឡូវនេះ ខ្ញុំមិនចង់មានន័យថា នៅពេលដែល ខ្ញុំនិយាយ "ចូរស្ងៀមស្ងាត់"...បើព្រះអម្ចាស់ ធ្វើការអ្វីមួយ អ្នក ចង់សរសើរតម្កើងព្រះ អម្ចាស់! នោះហើយជាការថ្វាយបង្គំដល់ព្រះ។ ប៉ុន្តែខ្ញុំចង់មានន័យថា "ការដែលក្រោកឡើង ហើយរត់ជុំវិញទីនេះ" អ្នកដឹងហើយថា នោះមិនមែនជាការគោរពទេ។ យល់ទេ? ហើយព្រះវិញ្ញាណបរិសុទ្ធ មិនមានទឹកចិត្ត មិនមានទឹកចិត្តនោះតេ។ យល់ទេ? គឺបែបនោះឯងគ្រាន់តែទុកពេលឱ្យខ្ញុំបន្តិច ហើយខ្ញុំគ្រាន់តែដោះស្រាយពីការនោះបន្ទាប់មក ជាថ្មីម្តងទៀតសូមមើល។ ប៉ុន្តែ ប្រសិនបើអ្នករាល់គ្នាស្តាប់!

214 តើអ្នកចាំពីសន្យាដំបូងរបស់ទ្រង់ទេ? "ចូរនាំមនុស្សឲ្យជឿអ្នក ហើយស្មោះត្រង់ គ្មានអ្វី ឈរចំលពោះការអធិស្ឋានបានឡើយ។" អ្នកចាំការនោះបានទេ? [ក្រុមជំនុំនិយាយថា "អាម៉ែន។"—Ed]។ត្រូវហើយ។ ហើយនោះហើយជា...ខ្ញុំមិនដែលឃើញវាមានការបរាជ័យឡើយ ហើយវាក៏នឹងមិនអាចកើតមានឡើយ។ ទ្រង់ គឺជាព្រះ។

215 ឥឡូវនេះ យើងនឹងប្រញាប់ជាមួយនឹង ជួរអធិស្ឋាន ដូច្នេះយើងទទួលបានមនុស្សជាច្រើនដូចដែលយើងឃើញ។ ប៉ុន្តែអ្នកទាំងនោះ គឺជាអ្នកដែលបានទទួលសន្លឹកកាតការអធិស្ឋាន និងអ្នកខ្លះទៀត ដែលមានសន្លឹក តែមិនបានហៅទេ នៅយប់នេះ សូមកាន់សន្លឹករបស់អ្នក យើងនឹងបានហៅ អ្នកដែរ។ ល្អណាស់ ។

216 ឥឡូវនេះ អ្នកនៅទីនោះ ដែលអត់មានកាតអធិស្ឋាន ចូរចងចាំ។ ឬអ្នកនៅ ទីនោះ មិនថាអ្នកមានកាតអធិស្ឋាន ឬអត់មាន គ្រាន់តែជឿទ្រង់ ដូចនៅហេព្រើរ ជំពូកទី៤នេះ។ "ទ្រង់ គឺសម្តេចសង្ឃ ដែលអាចស្គាល់ពីជំនឿរបស់យើងដោយបញ្ញាខ្សោយរបស់យើងបាន។" ឃើញទេប្រសិនបើ ទ្រង់គង់នៅ...ឃើញទេប្រសិនបើ ព្រះយេហូវ៉ា បង្ហាញអង្គទ្រង់ផ្ទាល់ទៅកណ្តាល ចំណោមរាស្ត្ររបស់ទ្រង់ដូចដែលទ្រង់ បានធ្វើនៅថ្ងៃ នៃទីក្រុងសូដុមដែរ។ ត្រឹមត្រូវណាស់។

217 ត្រូវហើយ។ ឥឡូវនេះ សូមអធិស្ឋានដោយការគោរពពិតប្រាកដ។ ឥឡូវចូរចាំព្រះបន្ទូលពីព្រះអោយច្រើនជាងពាក្យរបស់មនុស្ស។ ឥឡូវ បុរសម្នាក់នេះនៅទីនេះ ខ្ញុំ—ខ្ញុំមិនដែលស្គាល់គាត់ទេ។ ហើយខ្ញុំគិតថាគាត់ជា...មនុស្សចម្លែកចំពោះខ្ញុំ

អ្នក គឺជាមនុស្សដែលខ្ញុំមិនស្គាល់មែនទេ? [បងប្រុស និយាយថា "បាទ។"—Ed។] អ្នក គឺជាមនុស្សដែលខ្ញុំមិនស្គាល់។ យើងនឹងដឹងពីការមួយ នៅថ្ងៃមួយ យើងទាំងពីរ នឹងបានឈរនៅក្នុងវត្តមានរបស់ព្រះ យើងនឹងបានជួប ទ្រង់នៅទីនោះ។ នេះ គឺជាការជួបជុំលើកដំបូងរបស់យើង។

218 ឥឡូវបើអ្នកមកទីនេះ ប្រសិនបើអ្នកមានជម្ងឺ ខ្ញុំមិនដឹងទេវាអាចនឹងមានអ្វីផ្សេងទៀតយល់ទេ។ ប៉ុន្តែប្រសិនបើខ្ញុំ ប្រសិន—បើខ្ញុំដាក់ដៃលើអ្នក ហើយនិយាយថា "សរសើរតម្កើងព្រះអម្ចាស់! សូមអោយអ្នកបានជាសះស្បើយ។" តែបុណ្ណឹង។ អ្នកអាចជឿការនោះ។ ប៉ុន្តែអ្វីដែលនឹងកើតឡើង ប្រសិនបើទ្រង់ប្រាប់អ្នកពីអ្វីដែលជាកំហុសរបស់អ្នក? ឥឡូវ ចូរមើល អ្វីជាការខុសគ្នា បន្ទាប់ពីអ្នកដឹងពីអ្វីជាការបញ្ជាក់លក្ខណៈរបស់ទ្រង់។ ឃើញទេ នោះមិនមែនជាលក្ខណៈរបស់ខ្ញុំទេ។ ខ្ញុំជាមនុស្ស ខ្ញុំមិនដឹងពីអ្វីបន្តិចពីគាត់ទេ។ ខ្ញុំបានប្រាប់គាត់ថា "ខ្ញុំមិនស្គាល់អ្នកទេ។" គាត់ក៏មិនស្គាល់ខ្ញុំដែរ។ ប៉ុន្តែ អ្វីដែលអាចនឹង អាចកើតឡើងបាន? នោះជាការបញ្ជាក់លក្ខណៈរបស់ព្រះយេស៊ូវគ្រីស្ទ ដូចគ្នា នឹងកាលពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត។ ដោយដឹងថា នោះមិនមែនជារូបខ្ញុំទេ ព្រោះខ្ញុំមិនបានស្គាល់ បុរសម្នាក់នោះទេ។ ខ្ញុំនឹងលើកដៃរបស់ខ្ញុំឡើង *នេះ* គឺជាព្រះបន្ទូល។ ឃើញទេ? ខ្ញុំមិនស្គាត់គាត់ទេ។ គាត់ក៏មិនស្គាល់ខ្ញុំដែរ។ ប៉ុន្តែលក្ខណៈនៃព្រះយេស៊ូវគ្រីស្ទ...

219 ប្រសិនបើ ព្រះយេស៊ូវបានឈរនៅទីនេះ ហើយគាត់ឈឺ។ ប្រសិនបើ គាត់អាចនិយាយថា "ព្រះអម្ចាស់យេស៊ូវ សូមប្រោសខ្ញុំឱ្យជា។" តើព្រះយេស៊ូវនឹង មានបន្ទូលអ្វីទៅកាន់គាត់? "ខ្ញុំបានធ្វើរួចទៅហើយ។" នោះ គឺត្រូវហើយ? [ក្រុមជំនុំបាននិយាយថា "អាម៉ែន។"—Ed។]

220 "ទ្រង់បានរងរបួស ដោយព្រោះអំពើរំលងរបស់យើង ស្នាមរបួសរបស់ទ្រង់បានប្រោសយើង។" គ្រប់ការទាំងអស់ ទ្រង់ប្រោសលោះយើង នៅកាល់វ៉ារី។ ចាប់តាំងពីពេលនោះមក នោះគឺជាជំនឿ ចូរជឿការដែលទ្រង់បានសម្រេចនេះចុះ។ នោះត្រូវទេ? [ក្រុមជំនុំនិយាយថា "អាម៉ែន។"—Ed។] ត្រូវហើយ។

221 ឥឡូវ ឥឡូវនេះ ប្រសិនបើព្រះយេស៊ូវ មានព្រះជន្មរស់នៅ ហើយខ្ញុំបាននិយាយពីព្រះបន្ទូលរបស់ទ្រង់...វាមានភាពសាមញ្ញ នៃអ្នកដែល មានជំនឿ ជឿលើព្រះបន្ទូលរបស់ទ្រង់។ នៅពេលដែល ទ្រង់បានជួបខ្ញុំ នៅយប់នោះ ទ្រង់បានមានបន្ទូលថា "អ្នកនឹងអាចដឹងនូវអាថ៌កំបាំងក្នុងចិត្តរបស់ពួកគេ។ ពួកគេនឹងមិន

ជឿពីទីសម្គាល់ដំបូងនៃស្នារព្រះហស្តរបស់ទ្រង់ទេ ប៉ុន្តែពួកគេ ត្រូវតែជឿការមួយនេះ។ ឃើញទេ? ពួកគេមិនជឿ បន្ទាប់មកឈាមនឹងផ្លាសសារដល់ផែនដី។"

222 ដូចសម័យរបស់ លោក ម៉ូសេបានធ្វើដែរ។ ទ្រង់មានបន្ទូល "ការមិនជឿលើទីសម្គាល់ ទាំងពីរនោះ បន្ទាប់មកក៏បង្ហូរឈាមស្រោចនៅលើផែនដីទៅ។ ឃើញទេ ចាក់ទឹកនៅលើផែនដី ហើយវាបានក្លាយទៅជាឈាម។"

223 ឥឡូវនេះ សូមរកឲ្យឃើញ។ ប្រសិនបើខ្ញុំគ្រាន់តែដឹងពីអ្វី ដែលជាបញ្ហា របស់អ្នក ដើម្បីនឹងបំពេញ និងធ្វើឱ្យអ្នកបានជឿ តើអ្នកជឿទេ? [ប្អូនប្រុសម្នាក់ បាននិយាយថា "ប្រាកដណាស់។"—Ed។] អ្នកដឹងទេថានោះជាលក្ខណៈរបស់ មនុស្ស ខ្ញុំកំពុងនិយាយពី ព្រះយេស៊ូវគ្រីស្ទ។

224 មានបុរសម្នាក់ ខ្ញុំបានសម្លឹងទៅគាត់ ហើយក៏បានបែរត្រឡប់មកវិញ។ គាត់គឺជាស្រមោល។ វាមិនមានថ្នាំដែលអាចជួយបុរសម្នាក់នេះបានទេ។ គាត់ បានស្ថិតនៅក្នុងស្ថានភាពមួយដូចស្លាប់។ ត្រូវហើយ។ គាត់បានធ្វើការ វះកាត់ ហើយវាជាការវះកាត់ ក្រពេញប្រូស្តាត។ ហើយវាជាជំងឺមហារីក ហើយជាជំងឺមហារីកដែលបានរាលដាល ដល់គ្រប់ទីកន្លែងទាំងអស់ នៃរាង កាយ។ ប្រសិនបើជាត្រូវ សូមលើកដៃរបស់អ្នក។ មានតែព្រះទេ ដែលអាចព្យាបាលគាត់បាន។ [ប្អូនប្រុសម្នាក់បាននិយាយថា "ហាលេលូយ៉ា! ហាលេលូយ៉ា! ហាលេលូយ៉ា!"—Ed។] ប៉ុន្តែ មើល ខ្ញុំចង់និយាយ ទៅកាន់អ្នក បន្តិចលោក។ វិញ្ញាណលអាក្រក់អាចលាក់ ខ្លួន ពីកាំបិតរបស់វេជ្ជបណ្ឌិតបាន ប៉ុន្តែ វាមិនអាចលាក់ពីព្រះបានទេ។ តើអ្នកជឿទេ? តើអ្នកជឿវាទេ? ["អូហូ! អូហូ!"] បន្ទាប់មក ខ្ញុំបានអធិស្ឋាន នៅក្នុងព្រះនាម នៃ ព្រះយេស៊ូវគ្រីស្ទ សូមអោយ ការអាក្រក់ទាំងអស់បានចាកចេញពីគាត់ សូមអោយ បុរសម្នាក់នេះអាចរស់នៅ។ គ្មានអ្វីទេ គាត់គ្រាន់តែខ្សោយ។ ប្រសើរណាស់។

225 អ្នកនិងខ្ញុំ គឺជាមនុស្ស ដែលមិនស្គាល់គ្នា បុរសម្នាក់និងស្ត្រីម្នាក់បានជួបគ្នា។ ឥឡូវនេះ ជាមនុស្សម្នាក់ ដែលខ្ញុំមិនបានស្គាល់គាត់។ ហើយប្រហែលជា ជាស្ត្រី ដែលមិនស្គាល់ខ្ញុំ មិនមែនគ្រាន់តែអ្នក ស្គាល់ឈ្មោះ ឬរូបភាពខ្ញុំ ឬអ្វីមួយដូចនោះ។ ប៉ុន្តែយើងមិនបានស្គាល់គ្នាទេ។ នោះជាលក្ខណៈរបស់យើង។ យើងមិនបានស្គាល់ពីអ្វីផ្សេងទៀតឡើយ។ ប៉ុន្តែ លក្ខណៈពិសេសនៃព្រះគ្រីស្ទ ទ្រង់គឺជាព្រះបន្ទូលហើយព្រះបន្ទូលបានសន្យា សម្រាប់ថ្ងៃនេះ។ អ្នកបានឮ ខ្ញុំនិយាយ

ទេ។ បន្ទាប់មក លក្ខណៈពិសេសរបស់ទ្រង់ នឹងបានបញ្ជាក់នៅទីនេះ។ មិនមែនខ្ញុំជាអ្នកបញ្ជាក់អត្តសញ្ញាណរបស់ទ្រង់ទេ។ ខ្ញុំមិនបានស្គាល់អ្នកទេ។ តើអ្នកយល់ទេ។ ក្រុមជំនុំ—របស់យើងយល់ទេ? [ក្រុមជំនុំនិយាយថា"អាម៉ែន។"—Ed។] យល់ ទេ? ខ្ញុំ—ខ្ញុំ ជាមនុស្សម្នាក់។ ខ្ញុំគ្រាន់តែជា បងប្អូន របស់អ្នក?។

226 ដូចជាស្ត្រីម្នាក់នៅអណ្តូងទឹក និយាយអ្វីមួយដែលខុស អ្វីមួយខុសចំពោះអ្នក តើអ្នកត្រូវការអ្វី ឬអ្នកមកទីនេះដើម្បីអ្វី។ សូមឲ្យព្រះវិនិច្ឆ័យពី ការនោះ។ អ្នក កំពុងស្ថិតនៅក្នុងស្ថានភាពជម្ងឺខ្វះឈាម។ តើត្រូវទេ ឬមិនមែន? [ប្អូនស្រីនោះ បាននិយាយថា "ចាស"។—Ed។]

227 ខ្ញុំ—ខ្ញុំ និយាយត្រូវ មានមនុស្សខ្លះគិតថាខ្ញុំធ្វើការស្មាន។ ខ្ញុំមិនបានស្មានទេ។ ទេ។ ក្នុងមួយខណៈពេល ខ្ញុំមានអារម្មណ៍ថា មាននរណាម្នាក់។ អ្នកមិនអាចលាក់គំនិតរបស់អ្នកឥឡូវនេះបានទេ។ វាគឺជាការដែលខ្ញុំស្គាល់អ្នក ខ្ញុំបានដឹងពីការ អាក្រក់ពីរ ដែលមាននៅក្នុងខ្លួនអ្នក។ អ្នកឃើញ ខ្ញុំអាចហៅឈ្មោះរបស់អ្នកដែរ? ព្រះអាចធ្វើបាន ដូច្នេះចូរអ្នកគិតពីការនោះ។ អនុញ្ញាតអោយខ្ញុំ បានបង្ហាញអ្នក។

228 ចូរមើលមកទីនេះ ប្អូនស្រី សូមមើលមកខ្ញុំ។ ខ្ញុំមិនដឹងថា ទ្រង់បានប្រាប់នាងពីអ្វីទេ ប៉ុន្តែ ខ្ញុំ—ខ្ញុំស្គាល់ទ្រង់ថា ជានរណា។ នោះហើយ ជាលក្ខណៈ របស់ទ្រង់ដែលបានស្គាល់។ បាទ នោះជាស្ថានភាពនៃរោគខ្វះឈាម និងទឹក។

229 ឥឡូវនេះ នៅទីនេះ នៅទីនេះគឺជាអ្វីមួយ។ ឃើញទេ បើសិនអ្នកគិតថាគឺជាការស្មាន។ ក្មេងដែលអ្នកកំពុងអធិស្ឋាននៅទីនេះ។ [បងស្រីបាននិយាយថា "ចាស"—Ed។] ត្រូវហើយ។ វាមានបញ្ហានៅក្នុងបំពង់ក ["បាទ"។] វាជា ការកាត់សាច់បំពង់កចោល។ វាត្រូវទេ ["បាទ"។] ចូរយកកន្សែងនោះ ហើយដាក់នៅលើហើយជឿ។ ["បាទ"។] កុំសង្ស័យ។ វានឹងមិនត្រូវការវះកាត់នោះទេ។ ឥឡូវ សូមជឿអោយអស់ ពីចិត្តរបស់អ្នក។

230 ជំរាបសួរ? អំពីស្ត្រីម្នាក់នេះនៅទីនេះគឺថា អ្នកមានការភ័យខ្លាចអ្វីមួយ។ តើអ្នកខ្លាចថា ជំងឺមហារីកនោះវាកើតមកវិញទេ។ [ប្អូនស្រីបានយំ ហើយនិយាយថា "អូ!"។—Ed។] ឥឡូវនេះ សូមជឿចុះ ហើយវាមិនបានធ្វើដូច្នោះទេ។ សូមគ្រាន់តែទៅជឿ សូមជឿអោយអស់ពីចិត្ត របស់អ្នក។ លក្ខណៈពិសេស នេះ មិនមែនជារបស់ខ្ញុំទេ នេះជាលក្ខណៈពិសេសរបស់ព្រះ!

231 តើអ្នកជឿទេ ឥឡូវនេះ? [ក្រុមជំនុំនិយាយថា "អាម៉ែន។"—Ed។] នោះជាការដែលធ្វើឱ្យអ្នករាល់គ្នាជឿ ["អាម៉ែន!"]

232 ឥឡូវនេះខ្ញុំមិនស្គាល់អ្នកទេ។ខ្ញុំជាមនុស្សចម្លែកម្នាក់សម្រាប់អ្នក។ ព្រះស្គាល់ អ្នក។ តើអ្នកជឿទេ? អ្នកបានដឹងថា ខ្ញុំមិនស្គាល់អ្នកទេ ហើយអ្នក ក៏មិនស្គាល់ខ្ញុំដែរ ដូច្នេះ តើអ្នកជឿទេថា ព្រះវិញ្ញាណបរិសុទ្ធ ដែលមានបន្ទូលមកមិនមែនជាវិញ្ញាណរបស់ខ្ញុំទេ? ដោយសារតែខ្ញុំ គ្រាន់តែជាបុរសម្នាក់ ខ្ញុំមិនបានស្គាល់អ្នកទេ។ ប៉ុន្តែលក្ខណៈពិសេសនៃព្រះបន្ទូលសន្យានោះ គឺជាព្រះបន្ទូលដែលមុតជាងដាវមុខពីរទៅទៀត ឃើញទេ សូមគិត ដោយចិត្តរបស់អ្នកផ្ទាល់។

233 អ្នកគឺឈឺខ្លាំងណាស់។ អ្នកមានបញ្ហាស្ត្រី ដែលវាជាជម្ងឺ មហារីកស្បូន។ ហើយអ្នកបានទទួលយកប្រភេទនៃការព្យាបាលមួយចំនួន វាគឺជាការព្យាបាលដោយប្រើរ៉ាដ្យូម ឬអ្វីដែលធ្វើបានដើម្បីកំចាត់វាទាំងអស់នោះ ពីខ្លួនរបស់អ្នក។ ហើយអ្នកនឹង—អ្នកនឹងស្លាប់ ប្រសិនបើ ព្រះជាម្ចាស់ មិនប្រោសអ្នកអោយជា។ វាជាការពិត។ តើអ្នកជឿទេ ថាឥឡូវនេះទ្រង់នឹង ប្រោសអ្នក? [បងស្រីបាននិយាយថា "ចាស"។—Ed។] ព្រះនៃស្ថានសួគ៌ បន្ទោសដល់អារក្ស ដែលបានលាក់ ពីគ្រូពេទ្យនោះ។ ["អូ!"]គាត់អាចលាក់ពីរ៉ាដ្យូមបានតែមិនអាចលាក់ពី ព្រះវិញ្ញាណបរិសុទ្ធបានទេ។ ចូរជឿលើទ្រង់ឥឡូវចុះប្អូនស្រី។ កុំសង្ស័យអី ប៉ុន្តែសូមជឿវិញ។ ["ឱ ព្រះជាម្ចាស់ សូមប្រោសខ្ញុំអោយបានជាផង!"]

234 តើអ្នកជឿថា ព្រះអាចប្រោសជម្ងឺហឺតរបស់អ្នក អោយជាសះស្បើយបានទេ? [ប្អូនប្រុសនិយាយថា "បាទ។"—Ed។] តើអ្នកជឿពីការនោះទេ? បន្ទាប់មកចូរដើរតាមផ្លូវរបស់អ្នកទៅ ហើយអរសប្បាយដោយនិយាយថា "សូមអរគុណ ព្រះជាម្ចាស់។ ខ្ញុំជឿថាជំងឺហឺតរបស់ខ្ញុំនឹងបានជា។"

235 ជំរាបសួរ? អ្នកមានជម្ងឺប្រសៃប្រសាទ។ អ្នកបានមានវាអស់ រយៈពេលជាយូរមកហើយ។ ការនោះ វាបានបណ្ដាលមកពី ដំបៅក្រពះ ពោះវៀន វាមាននៅក្នុងក្រពះរបស់អ្នក ដែលធ្វើឱ្យអ្នកមានបញ្ហាក្រពះ របស់—របស់អ្នក។ ហើយអ្នកចង់...អ្នកចង់បរិភោគអាហារពេលល្ងាចរបស់អ្នក? តើអ្នកនឹងធ្វើអ្វី ដែល ខ្ញុំប្រាប់អ្នកឱ្យធ្វើទេ? ចូរបរិភោគដោយនូវព្រះនាម នៃព្រះអម្ចាស់យេស៊ូវចុះ។

236 តើអ្នកជឿដោយអស់ពីចិត្តរបស់អ្នកទេ? [បងស្រីបាននិយាយថា "ចាខ្ញុំជឿ។"—Ed។] អ្នកគឺជាស្ត្រីម្នាក់ដែលពូកែ បើតាមមើលទៅ។ តើអ្នកជឿថា ខ្ញុំជា

អ្នកបម្រើរបស់ព្រះទេ? ["អាម៉ែន"។] តើអ្នកជឿថាលក្ខណៈពិសេសរបស់ទ្រង់ អាចនឹងបង្ហាញនៅទីនេះបានទេ នោះជាព្រះបន្ទូលរបស់ទ្រង់ និងការសន្យា នៃថ្ងៃនេះ "ការដែលខ្ញុំធ្វើបាន អ្នកនឹងធ្វើដូចគ្នាដែរ?" ["អាម៉ែន។"] ខ្ញុំមិនអាចព្យាបាលទេ។ ទ្រង់បានធ្វើរួចហើយ ប៉ុន្តែលក្ខណៈពិសេសរបស់ទ្រង់បានបង្ហាញ និងអាចប្រាប់ពីបញ្ហារបស់អ្នកបាន។ អ្នកមានជម្ងឺ គឺជាបញ្ហារោគស្ត្រី។ ["ត្រូវហើយ។"] នៅពេលឥឡូវនេះ តើអ្នកជឿថា ព្រះជាម្ចាស់អាចព្យាបាលជម្ងឺរបស់អ្នកបានទេ? ["បាទ។អាម៉ែន។"] ចូរទៅតាមផ្លូវរបស់អ្នកចុះ វានឹងមិនរំខានអ្នកទៀតទេ។ សូមជឿអោយអស់ពីចិត្ត។

237 តើអ្នកជឿថា ខ្ញុំជាអ្នកបំរើរបស់ទ្រង់ទេ? [បងស្រីបាននិយាយថា "ចាស លោក។"—Ed។] ប្រសិនបើ ព្រះនឹងប្រាប់ខ្ញុំពីអ្វីដែលជាបញ្ហារបស់អ្នក តើអ្នកនឹងជឿថា នោះជាលក្ខណៈពិសេស នៃព្រះយេស៊ូវគ្រីស្ទទេ? វាគឺនៅខ្នង របស់អ្នក។ វានឹងមិនមានទៀតទេ។ ចូរជឿ អោយអស់ពីចិត្តចុះ។ សូមជឿ។

238 អញ្ជើញមក ទីនេះប្អូនស្រី។ អ្នកមានបញ្ហាក្រពះ។ ចូរជឿ អោយអស់ពីចិត្តរបស់អ្នក ហើយទៅបរិភោគអាហារពេលល្ងាចរបស់អ្នកចុះ។ បំភ្លេចវាចោលទៅ។ ព្រះយេស៊ូវគ្រីស្ទ នឹងប្រោសឱ្យអ្នកបានជាផងដែរ។

239 អញ្ជើញមក។ បញ្ហារបស់អ្នក គឺឈាមរបស់អ្នក។ អ្នកមានជំងឺទឹកនោមផ្អែម។ តើអ្នកជឿថា ព្រះនឹងប្រោសឱ្យអ្នកបានជាទេ? ចូរទៅតាមផ្លូវរបស់អ្នកចុះ ហើយនិយាយថា "សូមអរគុណ ព្រះអម្ចាស់យេស៊ូវ" ដែលបានប្រោសអ្នកឱ្យជាផងដែរ។ ចូរជឿ អោយអស់ពីចិត្តរបស់អ្នកចុះ។

240 អញ្ជើញមក។ ខ្នងរបស់អ្នក តើអ្នកជឿថា ព្រះនឹងព្យាបាលខ្នងរបស់អ្នក និងប្រោសអ្នកឱ្យជាដែរឬទេ? ចូរត្រឡប់ទៅវិញ ហើយចូរអរសប្បាយ ហើយនិយាយថា "សូមអរគុណ ព្រះអម្ចាស់យេស៊ូវ។"

241 អ្នក មានបញ្ហាជាមួយខ្នងរបស់អ្នកដែរ។ គ្រាន់តែដើរ ដោយពោលថា "សូមអរគុណ ព្រះអម្ចាស់។ ខ្ញុំពិតជា បានជាឡើងវិញ។" ចូរជឿ អោយអស់ពីចិត្តរបស់អ្នកចុះ។

242 អ្នកមានបញ្ហានៅខ្នងដូចគ្នា។ តើអ្នកដឹងវាមានសភាពយ៉ាងណាទេ? ចូរជឿអោយអស់ពីចិត្តរបស់អ្នក ឥឡូវនេះ ហើយចូរទៅតាមផ្លូវរបស់អ្នក ហើយទ្រង់បាន

ប្រោសអ្នកអោយជាដែរ។ ជឿថាព្រះយេស៊ូវគ្រីស្ទធ្វើឱ្យអ្នកផងដែរ។ "ប្រសិនបើ អ្នកអាចជឿថា ការទាំងអស់នេះ គឺអាចកើតមានឡើង។" ត្រូវហើយ។

243 តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំមិននិយាយទៅរកអ្នក! គ្រាន់តែ ដាក់ដៃ លើនាងតើអ្នកជឿថា នាងនឹងបានជាសះស្បើយទេ? ពួកគេបានដឹង នូវអ្វីដែលជាបញ្ហា។ តើអ្នកជឿថា នាងនឹងបានជាទេ? សូមមកទីនេះ។ ខ្ញុំសូមដេញវិញ្ញាណអាក្រក់ទាំងនេះក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ។ សូមអំណាច នៃព្រះបានប្រោសកុមារម្នាក់នេះអោយបាន ជាសះស្បើយផង។ អាម៉ែន។ កុំសង្ស័យ កុំសង្ស័យលើអ្វីទាំងអស់ហើយនាងនឹងបានជាសះស្បើយ។ ជឿដោយអស់ពីបេះដូងរបស់អ្នក។

244 ប្រសិនបើព្រះជាម្ចាស់ មិនបានប្រោសអ្នក អ្នកនឹងដើរកាន់ឈើច្រត់ នៅថ្ងៃណាមួយ ជាមួយនឹងជម្ងឺរលាកសន្លាក់របស់អ្នក។ ប៉ុន្តែតើអ្នកជឿថា ព្រះជាម្ចាស់ នឹងប្រោសជំងឺរលាកសន្លាក់របស់អ្នកបានជា ឬទេ? បន្ទាប់មក ចូរនិយាយថា "សូមអរគុណ ព្រះជាម្ចាស់។ ខ្ញុំនឹងជឿដល់ទ្រង់ហើយទ្រង់នឹងប្រោសខ្ញុំ អោយបានជាផងដែរ។" មែនហើយ។

245 សូមអញ្ជើញមកនេះ ឥឡូវនេះ។ វាជាបញ្ហាអាយុរបស់អ្នក។ អ្នកពិតជាមានការភិតភ័យណាស់។ អ្នកពិតជា មានការភិតភ័យណាស់ នៅល្ងាចនេះ។ នៅពេលដែលអ្នកធ្វើការ និងការធ្វើអ្វីគ្រប់យ៉ាង អ្នកតែងតែមានការភិតភ័យ។ អ្នកជឿទេ ឥឡូវនេះ? វានឹងមិនរំខានអ្នកទៀតទេ។ ចូរទៅតាមផ្លូវរបស់អ្នក ហើយនិយាយថា "សូមអរគុណ ព្រះអម្ចាស់យេស៊ូវ។"

246 អញ្ជើញមកនេះ លោក។ តើអ្នកជឿថាព្រះជាម្ចាស់នឹងប្រោស ជម្ងឺបេះដូងរបស់អ្នកបានទេ? [ប្អូនប្រុសនិយាយថា "បាទ។"—Ed។] ទ្រង់នឹង ប្រោសជម្ងឺបេះដូងរបស់អ្នកអោយបានជា ដោយគ្រាន់តែដើរទៅ ហើយនិយាយថា "សូមអរគុណព្រះអម្ចាស់ ខ្ញុំនឹងជឿទ្រង់ អោយអស់ ពីចិត្តរបស់ខ្ញុំ។"

247 ព្រះជាម្ចាស់ ទ្រង់នឹងប្រោសជំងឺបេងរបស់អ្នក អោយបានជា។ តើអ្នកជឿទ្រង់ដោយអស់ពីចិត្ត របស់អ្នកទេ? [ប្អូនប្រុសនិយាយថា "ខ្ញុំជឿ។"—Ed។] មែនហើយ។ ចូរទៅតាមផ្លូវរបស់អ្នក ហើយដើរដោយអំណរ និងនិយាយថា "សូមអរគុណ ព្រះអម្ចាស់យេស៊ូវ។"

248 ចុះអ្នកនៅខាងក្រៅនោះ តើអ្នកជឿទេ? ចុះអ្នករាល់គ្នាវិញ? មានអ្នកខ្លះ ក្នុងចំនោមអ្នករាល់គ្នាគឺជឿ។

249 បុរសម្នាក់ អង្គុយនៅទីនេះ ដោយមានជម្ងឺ រលាកទងសួត តើអ្នកជឿថា ព្រះនឹងប្រោសជម្ងឺរលាកទងសួតរបស់អ្នកអោយជាបានទេ? ប្រសើរណាស់ អ្នកនឹងបាន ទទួលនូវអ្វី ដែលអ្នកបានទូលសូមនោះ។ អេម៉ែន។

250 សម្ពាធឈាមខ្ពស់ ម្នាក់ដែល អង្គុយពីក្រោយគាត់នោះ។ តើអ្នកជឿថា ព្រះនឹងប្រោសជម្ងឺសម្ពាធឈាមខ្ពស់របស់អ្នកអោយជាបានឬ? វានឹងចេញពីអ្នក ណាលោក។ ខ្ញុំមិនស្គាល់គាត់ទេ ហើយក៏មិនដែល ឃើញគាត់ដែរ កាលពីមុន។

251 និយាយថា លោក តើលោកជឿថា ជម្ងឺសន្លាក់សាច់ដុំរបស់លោក ដែលមានភាពតឹងណែននៃសាច់ដុំ តើលោកជឿថា ព្រះនឹងប្រោសអោយលោក បានជាទេ? លោកជឿទេ? លើកដៃរបស់លោកឡើង ប្រសិនបើ លោកជឿ។ ល្អ។

252 ប្រពន្ធរបស់អ្នកអង្គុយនៅទីនោះ នាងការរំខាន ដោយសារបញ្ហា ក្នុងប្រហោងឆ្អឹងរបស់នាង។ តើអ្នកជឿថា វានឹងចេះពីអ្នកទេ បងស្រី?

253 នៅទីនេះ មានស្ត្រីម្នាក់ដែលអង្គុយ នៅពីក្រោយពួកយើង នៅទីនេះ នាងមានជម្ងឺសរសៃប្រសាទ។ តើអ្នកជឿថា ព្រះនឹងប្រោសជម្ងឺប្រសៃប្រសាទ របស់អ្នកអោយជាបានទេ ប្អូនស្រី?

254 នេះគឺប្អូនស្រីម្នាក់ ពាក់អាវក្រៅ ក្រហមនេះ នាងកំពុងអង្គុយនៅទីនោះ។ នាងមានឆ្អឹងដុះនៅក្នុងខួរក្បាល។ តើអ្នកជឿថា ព្រះនឹងប្រោសជម្ងឺរបស់អ្នកអោយបានជាឬទេ? លើកដៃរបស់អ្នកឡើង ប្រសិនបើអ្នកជឿ។

255 អ្នកទាំងអស់គ្នា នៅក្នុងចំណោមយើងនៅទីនេះនៅយប់នេះ ជឿថាលក្ខណៈនៃព្រះយេស៊ូវគ្រីស្ទនៅក្នុងចំនោមយើង សូមលើកដៃឡើង ហើយនិយាយថា "ខ្ញុំជឿ" [ក្រុមជំនុំមានអំណរសប្បាយ ហើយបាននិយាយថា "ខ្ញុំជឿ!"—Ed។]

256 ការទាំងអស់គឺត្រូវបានបញ្ចប់ត្រឹមនេះ យើងនឹងទទួលយកទ្រង់ ជាអ្នកសង្គ្រោះរបស់យើង ចូរក្រោកឈរឡើងហើយនិយាយថា "ខ្ញុំជឿ។" លើកដៃឡើង។ ចូរក្រោកឡើង ហើយដើរចេញពីកៅអីរបស់អ្នកឬ អ្នកចង់ធ្វើមេចក៏បាន។ ព្រះយេស៊ូវគ្រីស្ទទ្រង់ នៅតែដដែល ទ្រង់ដូចជាពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូតតទៅ។ ខ្ញុំសូមប្រគល់ទ្រង់ទៅឱ្យអ្នក នៅក្នុងព្រះនាមនៃ ព្រះអម្ចាស់។

## ព្រះសម្គាល់អង្គទ្រង់ដោយ លក្ខណៈពិសេសរបស់ទ្រង់ KHM64-0320

(God Identifying Himself By His Characteristics)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅល្ងាច ថ្ងៃសុក្រ ថ្ងៃទី 20 មីនា 1964 នៅវិទ្យាល័យ Denham Springs, Denham Springs, Louisiana, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែរអាត់ថតចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបកប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក។

KHMER

©2020 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG